# ការសម្ភាសរបស់អ្នកមីង ជឹម វ័ន្ត

កៈ អ្នកសម្ភាសឈ្មោះដាង ស៊ីអ៊ាវ ខៈ អ្នកទទួលការសម្ភាសឈ្មោះ ជឹម វ័ន្ត។

## ការសង្ខេបប្រវត្តិរបស់អ្នកមីង ជឹម វ័ន្ត

អ្នកមីងជឹម វ័ន្តមាមអាយុ៤៦ឆ្នាំ នៅក្នុងឆ្នាំ២០២០ ភេទស្រី មានទីលំនៅបច្ចុប្បន្ននៅភូមិចំរើន ឃុំស្រែសង្គម ស្រុកកោះញ៉ែក ខេត្តមណ្ឌលគិរី។

កៈ ចឹងជាដំបូងខ្ញុំអរគុណច្រើនមីងដែរបានអោយខ្ញុំពិភាក្សាជាមួយមីងទាក់ទងពីប្រវត្តិរបស់មីង ហើយការសម្ភាសទាំងអស់នេះត្រូវបានរៀបចំដោយសកលវិទ្យាល័យមួយដែរនៅអាមេរិចដែរមានឈ្មោះថាBYU ហើយដោយសារតែសកលវិទ្យាល័យមានគោលបំណងចង់រក្សាពីប្រវត្តិប្រជាជនខ្មែរដើម្បីទុកអោយកូនចៅជំនាន់ក្រោយពួកគាត់បានស្គាល់ហ្នឹងបានដឹងពីប្រវត្តិឪពុកម្ដាយហ្នឹងដូនតាជាពិសេសអោយចៅៗរបស់មីង រឺមួយក៏កូនក្មួយអីដឹងពីប្រវត្តិរបស់មីងដែរមីងបានរៀបរាប់ ចឹងសំរាប់មីងយល់ព្រមដើម្បីអោយក្មួយដាក់ការសម្ភាសទាំងអស់ហ្នឹងទៅក្នុងវេបសាយសាលាទេមីង?

ខៈ ចា៎!

កៈ បាទចឹងសំរាប់ខ្ញុំជាអ្នកសម្ភាសមីងខ្ញុំមានឈ្មោះថាដាង ស៊ីអ៊ាវហើយថ្ងៃខែដែរខ្ញុំសម្ភាសមីងគឺនៅថ្ងៃទី២៦ខែ៤ឆ្នាំ២០២០ ហើយការសម្ភាសទាំងអស់ហ្នឹងគឺធ្វើឡើងនៅភូមិហ្នឹងភូមិអីគេមីង?

ខៈ ភូមិចំរើន។

កៈ ភូមិចំរើន ចុះឃុំ?

ខៈ ឃុំស្រែសង្គមហ្នឹងហើយ!

កៈ ឃុំស្រែសង្គម?

ខៈ ស្រុកកោះញ៉ែក។

កៈ ស្រុកកោះញ៉ែក ខេត្តមណ្ឌលគិរី?

ខៈ ហ្នឹងហើយ!

កៈ ចឹងសំរាប់មីងឈ្មោះពេញទាំងត្រកូលម៉ងឈ្មោះអីគេមីង?

ខៈ ជឹម វ័ន្ត។

កៈ ជឹម វ័ន្តចុះមានឈ្មោះហៅក្រៅអត់មីង?

ខៈ អត់មានទេ។

កៈ ចុះកាលពីក្មេងធ្លាប់មានឪពុកម្ដាយរឺមួយក៏បងប្អូនហៅឈ្មោះមីងអីផ្សេងអត់?

ខៈ អត់ទេហៅតែឈ្មោះហ្នឹង!

កៈ ចឹងហោសមីងចុះអើចឹងមីងសព្វថ្ងៃមីងអាយុប៉ុន្មានហើយ?

ខៈ សែប្រាមួយ។

កៈ សែសិបប្រាំមួយឆ្នាំ?

ខៈ ចា៎!

កៈ មីងមានចាំមីងកើតនៅថ្ងៃខែឆ្នាំណាមីងមានចាំអត់?

ខៈ អត់ចាំផង។

កៈ ចុះឆ្នាំមួយពាន់ប្រាំបួនរយប៉ុន្មានមីងអត់ចាំទេ?

ខៈ
អត់ចាំផងបើរត់ពីចូលប៉ុលពតណុងអត់ចាំផងបើនៅបីទទឹងប៉ុនដឹងតែឆ្នាំថោះរាប់ទៅវាសែ
..។

កៈ ឆ្នាំថោះ?

ខៈ ហ្នឹងហើយឆ្នាំថោះរាប់ទៅវាសែប្រាំមួយឆ្នាំហ្នឹង!

កៈ អូ៎ប៉ុន្តែឆ្នាំមួយពាន់ប្រាំបួនរយប៉ុន្មានអត់ចាំទេណេះ?

ខៈ អត់ចាំទេបើម៉ែនៅបីទទឹងខ្ញុំអត់ដឹងអីផង។

កៈ អូ៎បាទមីងចុះមីងអើកន្លែងកំណើតដែរមីងកើតម៉ងមីងកើតនៅណា?

ខៈ កើតនៅសៀមរាប។

កៈ សៀមរាបហោស?

ខៈ ចា៎!

កៈ ភូមិអី?

ខៈ ដឹងភូមិអីទេម៉ែខ្ញុំបានស្គាល់ស្រុកជីក្រែង ខេត្តសៀមរាប។

កៈ អូ៎ស្រុកជីក្រែងហោស?

ខៈ ជីក្រែងស្រុក។

កៈ ជីក្រែង?

ខៈ ជីក្រែងហីម៉ែ?

កៈ បាទ!

ខៈ ជីក្រែងៗ។

កៈ ជីក្រែងខេត្តសៀមរាប?

ខៈ ខេត្តសៀមរាប។

កៈ បាទមីងចុះអើមីងមានបងប្អូនបង្កើតប៉ុន្មាននាក់មីង?

ខៈ រាល់ថ្ងៃហ្នឹងនៅតែបីនាក់ហ្នឹងបងប្អូនបង្កើត។

កៈ ប៉ុន្តែទាំងមានអ្នកស្លាប់អត់?

ខៈ ស្លាប់អស់ប៉ុន្មាននាក់ដែរបងសុត
បងសុនស្លាប់បីបួននាក់ដែរបីបួននាក់ហើយខ្ញុំមិនស្គាល់ទេម៉ែបានស្គាល់ខ្ញុំមិនស្គាល់ផង។

កៈ អូ៎មីងចឹងមីងដឹងៗតែអ្នកនៅរស់ប៉ុន្មានបីនាក់ណេះមីង?

ខ៖ ចាំដឹងតែនៅរស់រាល់ថ្ងៃបងប្អូនខ្ញុំមានតែបីនាក់ទេបង្កើតហាស!

ក៖ អូ៎!

ខ៖ ចាំ!

ក៖ ចុះមីងកូនទីប៉ុន្មានទៅចឹង?

ខ៖ ខ្ញុំខ្ញុំកូនទីពីរ។

ក៖ ទីពីរហោស?

ខ៖ ហ្នឹងហើយ!

ក៖ ចុះអើស្រីប៉ុន្មាន..?

ខ៖ ម៉ែខ្ញុំយកប្ដីមុនខ្ញុំបានកូនទីពីរ។

ក៖ អូ៎!

ខ៖ ទាំងបងស្រីមួយខ្ញុំមួយ។

ក៖ អូ៎!

ខ៖ ចាំ!

ក៖ ដល់ពេលក្រោយមកមានក្រោយមួយទៀត?

ខ៖ ក្រោយមកម៉ែខ្ញុំយកប្ដីក្រោយណុងបានកូនបីហ្នឹងសព្វថ្ងៃហ្នឹង!

ក៖ អូ៎!

ខ៖ អូ៎បានពីរទៀតហីម៉ែតែពីរទេបានតែពីរទេម៉ែយកប្ដីក្រោយបានពីរទៀត។

ក៖ អូ៎បាទ!

ខ៖ ចាំ!

ក៖ ប៉ុន្តែចឹងមីងបងប្អូនបួននាក់?

ខ៖ ហ្នឹងហើយរស់នៅរាល់ថ្ងៃហ្នឹងនៅតែបីហ្នឹង!

ក៖ បីហោស?

ខ៖ រស់នៅរាល់ថ្ងៃតែបីនាក់ទេបង្កើតៗហាស!

ក៖ បាទមីង!

ខ៖ បង្កើតៗ។

ក៖ ចុះមីងអើមីងអាចប្រាប់ឈ្មោះពួកគាត់បានទេពួកគាត់នៅណាខ្លះពួកគាត់ឈ្មោះអីគេចឹងហាសណាស់?

ខ៖ អូ៎ជឹម រឿន ជឹមវ៉ាន់។

ក៖ ប៉ុន្តែពួកគាត់នៅកោះញ៉ែកហ្នឹងទាំងអស់គ្នាតើហី?

ខ៖ នៅទាំងអស់គ្នានៅភូមិចំរើនតែមួយ។

ក៖ អូ៎គាត់ធ្វើអីគេទៅ?

ខ៖ មានធ្វើអីប្អូនខ្ញុំគ្មានធ្វើអីទេដើរដូចថាធ្វើការអោយគេចឹងទៅ ហើយប្អូនខ្ញុំអាប្រុសបើកអាត្រាក់អោយគេចឹងទៅបើកឡានអោយគេទៅ។

ក៖ តែគាត់មានក្រុមគ្រួសារអស់ហើយណេះមីង?

ខ៖ ក្រុមគ្រួសារអស់ហើយគ្រួសារគេបែកៗអស់ហើយ!

ក៖ អូ៎ហើយចុះបងមីង?

ខ៖ បងឆ្កួតអត់ដឹងអីទេក្អួយអើយនៅឆ្កួតនៅផ្ទះអោយប្អូនមើលណុងនិយាយមិនដឹងអីផងណុង។

ក៖ អើម៉េចចឹង?

ខ៖ ឆ្កួតមានប្ដីនៅស្រុកណុងដាប់កូនទៅដូចទៅឆ្កួតនិយាយលែងដឹងអីដើរស្រាតដោះអាវរើកក់អីម្នាក់ឯងចឹងទៅ។

ក៖ មានអារម្មណ៍ថាគាត់មានជំងឺផ្លូវចិត្តអីចឹងហាសណេះមីងណេះ?

ខ៖ ប្រហែលហើយព្រោះអីម៉ែគាត់បែកអាពតមកហ្នឹងគាត់ទៅលេងស្រុកគាត់ថានៅមើលយាយនៅរើសឆ្អឹងយាយ យាយចាស់ដែរហើយទលមានប្ដីគេធ្វើបាបទៅចាប់ផ្ដើមឆ្កួតចឹងរហូតទៅ។

ក៖ អូ៎ប្ដីគាត់ធ្វើបាបគាត់ហោស?

ខ៖ ហ្នឹងហើយម៉ែមើលអស់រាប់ដំឡឹងហ្នឹងមើលអត់ជាទេលោកគ្រូ។

ក៖ អូ៎!

ខ៖ ម៉ែមើលដែរតើមើលឡើងអស់រលីងហោសរាប់ដំឡឹងហោសមាសសន្លឹកមាសអីលក់អស់ហើយ!

ក៖ អូ៎!

ខ៖ អត់ជាទេ។

ក៖ ចុះឥឡូវគាត់នៅជាមួយនរណាគេ?

ខ៖ នៅជាមួយប្អូនខ្ញុំជីម រឿនហ្នឹង!

ក៖ អូ៎!

ខ៖ នៅភូមិចំរើនហ្នឹងដែរ។

ក៖ បាទ!

ខ៖ ចាំ!

ក៖ ផ្ទះនៅជិតៗគ្នាតើមីង?

ខ៖ នេះទៅដល់កន្លែងផ្ទះម្ដុំ។

ក៖ ទីប៉ុន្មានទីពីរ?

ខ៖ ហួសភូមិចំរៀនយើងហ្នឹងងាកមកអាផ្ទះគេខាងណោះតៀមផ្ទះអាគេធ្វើរបងអាគារគេធ្វើរបងទាំងអស់អាបង្គោលខៀវណុង។

ក៖ អាជិតដល់អើសាលាឃុំហ្នឹងហេស?

ខ៖ អត់ទេលោកគ្រូឯងអើអូនឯងជិះម៉ូតូពីហ្នឹងទៅងាកខាងស្តាំដៃអាបង្គោលឈើរបងគេវ៉ៃអាជញ្ជាំងគេលាបថ្នាំព័ណខៀវហ្នឹងខាងស្តាំដៃហ្នឹង!

ក៖ អូ៎!

ខ៖ ហួសផ្ទះហ្នឹងផ្ទះម៉ែហើយ!

ក៖ អូ៎បាទមីង!

ខ៖ ហ្នឹងហើយ!

ក៖ ប៉ុន្តែចឹងពួកគាត់អើធ្វើស្រែធ្វើអីដែរ?

ខ៖ អត់មានស្រែធ្វើទេប្អូនខ្ញុំពីរនាក់ហ្នឹងអត់មានទេ។

ក៖ មានតែមីងណោះ?

ខ៖ ហ្នឹងហើយប្អូនខ្ញុំអត់មានដីស្រែទេបើអាមួយដីភូមិក៏គ្មានដីស្រែក៏គ្មានដែរនៅហ្នឹងនៅដីភូមិផ្ទះបងទេ។

ក៖ អូ៎!

ខ៖ នៅដីភូមិបងថ្លៃខ្ញុំហាស!

ក៖ បាទៗមីងបាទ!

ខ៖ ហ្នឹងហើយ!

ក៖ ប៉ុន្តែកូនចៅគាត់ធំៗអស់ហើយណោះមីងណោះ?

ខ៖ មានតែអាហ្នឹងធំមួយហើយអាមីស្រីមួយហើយប្អូនខ្ញុំអាប្រុសហ្នឹងកូនវាដើរតេកគាក់ៗហ្នឹងមួយ។

ក៖ អូ៎បាទមីង!

ខ៖ ហ្នឹងហើយ!

ក៖ ចុះឪពុករបស់មីងឈ្មោះអីគេមីង?

ខ៖ ឪពុកដឹងក្តីមកហ្នឹងដឹងតែឪពុកចុងហ្នឹងម៉ងខ្ញុំដឹងក្តីមកជឹម វ័ន្តហ្នឹងតែម៉ង។

ក៖ អូ៎!

ក៖ ឪពុកបង្កើតឈ្មោះរន ប៉ុន្តែមិនដឹងស្លាប់មិនដឹងរស់ជំនាន់ប៉ុលពតបែកពីម៉ែរកបែកខ្មែកគ្នាហាស!

ក៖ អូ៎!

ខ៖ ចាំ!

ក៖ ដឹងតែឪពុកចុងហ្នឹងទេ?

ខ៖
ដឹងតែឪពុកចុងទេខ្ញុំដឹងក្ដីឡើងគាត់ចិញ្ចឹមខ្ញុំពីកំពស់នេះមកខ្ញុំដឹងក្ដីឡើងខ្ញុំដឹងតែឪពុកហ្នឹងម៉ង។

ក៖ ប៉ុន្តែឪពុកអើឪពុកចិញ្ចឹមហ្នឹងឈ្មោះដឹម វ័ន្ត?

ខ៖ ឈ្មោះដឹម។

ក៖ ឈ្មោះដឹមហោស?

ខ៖ ចាំតែខ្ញុំឈ្មោះវ័ន្ត។

ក៖ អូ៎!

ខ៖ ប៉ុនខ្ញុំដាក់ត្រកូលគាត់ម៉ងទៅ។

ក៖ បាទមីង!

ខ៖ ហ្នឹងហើយ!

ក៖ ប៉ុន្តែឪពុកបង្កើតឈ្មោះរន?

ខ៖ ឈ្មោះរន។

ក៖ ឈ្មោះរនហោស?

ខ៖ ចាំ!

ក៖ អូចឹងយើងបែកគ្នាតាំងពីប៉ុលពតហ្នឹងរហូតទៅ?

ខ៖
ហ្នឹងហើយបែកទាល់ឥឡូវពីប៉ុលពតណុងមកដល់ដឹងក្ដីម៉ែយកពុកក្រោយហ្នឹងបានខ្ញុំស្គាល់ឪពុកក្រោយហ្នឹងទេ។

ក៖ អូ៎បាទមីងបាទ!

ខ៖ ឪពុកមុនខ្ញុំមិនស្គាល់ទេ។

ក៖ ប៉ុន្តែឪពុកក្រោយហ្នឹង..?

ខ៖ គាត់ស្លាប់ហើយ!

ក៖ គាត់ស្លាប់ហើយហោស?

ខ៖ ស្លាប់ហើយ!

ក៖ ស្លាប់យូរហើយណេះមីងណេះ?

ខ៖ ស្លាប់បីបួនឆ្នាំហើយបួនឆ្នាំឆ្នាំហ្នឹងហីបីឆ្នាំបួនឆ្នាំឆ្នាំហ្នឹងហើយ!

ក៖ អូ៎គាត់ស្លាប់ដោយសារជំងឺហាសណេះមីង?

ខ៖ ជំងឺចាស់រលេះដូចថាគ្រសក់ទុំរលេះហាសក្អួយ។

ក៖ គាត់អាយុប៉ុន្មានហើយដល់ឥឡូវ?
ខ៖ ប៉ែត្រប្រាំបី។

ក៖ អូ៎ប៉ែត្រប្រាំបី?

ខ៖ ហ្នឹងហើយ!

ក៖ អូ៎ចឹងយាយក៏ចាស់ដែរណេះ?

ខ៖ ចា៎?

ក៖ យាយក៏ចាស់ដែរណេះមីងចឹង?

ខ៖ ហ្នឹងយាយហ្នឹង!

ក៖ យាយអាយុប៉ុន្នានហើយឥឡូវ?

ខ៖ យាយចិតបី។

ក៖ អូ៎ប៉ុន្តែយាយឈ្មោះអីគេ?

ខ៖ យាយឈ្មោះមុត សុក។

ក៖ អូ៎ចុះអើចឹងឪពុករបស់មីងកាលគាត់នៅរស់ហ្នឹងគាត់ធ្វើអីគេសំរាប់ចិញ្ចឹមជិវិត ចិញ្ចឹមកូនចៅហាសមីង?

ខ៖ ឪពុកខ្ញុំឪពុកចុងហ្នឹង?

ក៖ ឪពុកចុង។

ខ៖ គាត់ធ្វើស្រែធ្វើចំការដាំដំណាំ។

ក៖ អូ៎បាទ!

ខ៖ ចា៎!

ក៖ ចុះអើគាត់ស្លូតដែរមីងណេះ?

ខ៖ មិនដែរធ្វើបាបខ្ញុំទេតាំងពីខ្ញុំដឹងក្តីមកមិនដែរធ្វើបាបខ្ញុំទេហើយស្រឡាញ់ខ្ញុំជាងកូនគាត់បង្កើតទាំងអស់។

ក៖ អូ៎!

ខ៖ ស្រឡាញ់ខ្ញុំដូចថាដឹងដូចថាដឹងខុសត្រូវដឹងដូចថាខោអាវឪពុកប្រឡាក់អីចឹងចេះយកមកគក់មកបោកក៏គាត់កូនបង្កើតនៅក្បែរសូម្បីតែសំលមួយវែកក៏មិនយកទៅអោយដែរដល់ចឹងខ្ញុំកូនចុងហ្នឹងដូចថាយើងដឹងគាត់ចឹងគាត់ស្រឡាញ់យើង។

ក៖ អូ៎!

ខ៖ ស្អីមួយម៉ាត់ក៏ដោយខ្ញុំមិនដែរតែកូនបង្កើតគាត់គាត់អត់ដែរគិតអត់គាត់ចឹងគាត់ដូចមិនសូវអារម្មណ៍ហាស!

ក៖ បាទមីង!

ខ៖ គាត់យល់មកតែលើយើងហ្នឹង!

ក៖ អូ៎!

ខ៖ សូម្បីតែភ្ជួយមុងពុកខោអាវប្រឡាក់ខ្ញុំប្រមូលបោកតើរាល់គេថាតើគេថាជិតខាងគេថាកូនគេនៅក្បែរណុងគេមិនមកផងហើយហ្វែងឪពុកចុងសោះហែងបោកហែងសំអាត ឪពុកចុងគាត់ចិញ្ចឹមយើងដូចតែឪពុកបង្កើតតាំងពីកំពស់ណេះនេះ។

ក៖ បាទមីង!

ខ៖ ដូចថាឪយើងបង្កើតហើយគាត់ជាអ្នកបង្កកំណើតអោយយើងដែរប៉ុនណុងហោស!

ក៖ បាទត្រូវ!

ខ៖
ហ្នឹងហើយដល់ចឹងគាត់ស្រឡាញ់ដែរខ្ញុំតែគាត់ស្លាប់ណុងក៏លុយកាក់អីមិនថានេះអីយកមកអោយខ្ញុំខ្ញុំអត់លុយអីចឹងយកមកអោយទៅគាត់ធ្វើអាចារ្យហោស!

ក៖ អូ៎!

ខ៖ គាត់អាចារ្យខ្មោច។

ក៖ តែគាត់នៅហ្នឹងដែរហោសមីងពីមុន?

ខ៖ នៅភូមិចំរើនហ្នឹងប៉ុននៅផ្ទះម៉ែណុងផ្ទះប្អូណខ្ញុំនៅហោស!

ក៖ អូ៎ដល់ពេលគាត់ស្លាប់បានយាយមកនៅហ្នឹង?

ខ៖ ចាំបើប្អូនខ្ញុំវាចិត្តអត់បានមើលម៉ែទេ។

ក៖ អូ៎ចឹងហោស?

ខ៖
អត់បានទេតែលុយកាក់អីក៏វាមិនផ្តល់អោយដូចខ្ញុំនិយាយប្រាប់លោកគ្រូឯងចឹងលើតែខ្ញុំទេមីពួកអស់ណុងវាអត់ដឹងទេ។

ក៖ បាទ!

ខ៖ យើងថាម៉ែឈឺម៉ែអីចឹងវាថាវាគ្មានអីចឹងទៅហើយយើងទៅថាម៉េច។

ក៖ ពិបាកដែរចឹង?

ខ៖ ពិបាកទាល់តែខ្ញុំហ្នឹងសូម្បីតែម៉ែនៅលើផ្ទះហ្នឹងខោអាវម៉ែក៏វាមិនដែរបោកវាមិនដែរថាម៉ែធ្វើម្ហូបស៊ីទេវាអត់រវល់ទេ។

ក៖ អូ៎!

ខ៖ ហើយចឹងយើងទុកគាត់ចោលម៉េចយើងជាបងមិនយកមកមើលមកថែ។

ក៖ ត្រូវ!

ខ៖ វាអត់គិតផងណុង។

ក៖
បាទមីងចុះមីងអើម្តាយរបស់មីងកាលគាត់នៅក្រមុំរឺគាត់នៅពីមុនយកឪពុកមីងដំបូងគាតធ្វើអីគេសំរាប់ចិញ្ចឹមជីវិតចិញ្ចឹមកូនចៅយាយ?

ខ៖ ម៉ែខ្ញុំ?

ក៖ បាទយាយ!

ខ៖ ដឹងអីម៉ែម៉ែធ្វើតែស្រែដែរ។

កៈ យាយធ្វើតែស្រែណេះ?

ខៈ ចា៎!

កៈ អូ៎!

ខៈ គ្មានធ្វើអីទេខ្ញុំដឹងតែធ្វើតែស្រែមួយមុខ។

កៈ អូ៎ចឹងយាយធ្វើ...?

ខៈ មិនដែរចេះអីម៉ង។

កៈ អូ៎ប៉ុន្តែយាយស្លូតហាសណេះ?

ខៈ មានអីគាត់នៅតែជាមួយកាលគាត់នៅជាមួយតាគាត់នៅផ្ទះណុង
ដល់ពេលអត់ពីតាទៅគាត់ឈឺចឹងប្អូនខ្ញុំអត់យកចិត្តទុកដាក់មើលគាត់ចឹងខ្ញុំយកគាត់មក
មើលថែទៅ។

កៈ អូ៎បាទមីង!

ខៈ ហ្នឹងហើយ!

កៈ មីងធ្លាប់មានអនុស្សាវរីយ៍ជាមួយឪពុកម្តាយមីងកាលនៅក្មេងៗអត់មីង?

ខៈ អត់ដែរផង។

កៈ ធ្លាប់ទៅធ្វើស្រែធ្វើអីជាមួយគាត់អីចឹងហាស?

ខៈ អូ៎ទៅទៅធ្វើស្រែធ្វើអីជាមួយម៉ែពុកហ្នឹងហើយ!

កៈ អូ៎ប៉ុន្តែមានធ្លាប់លក្ខណៈដើរលេងរឺមួយក៏ស៊ីផ្សេងៗជាមួយពួកគាត់អត់?

ខៈ ទៅដូចថាម៉ែទៅរកមាន់ជ្រូកអីចឹងគាត់ជួញរកមាន់រកជ្រូក។

កៈ បាទ!

ខៈ រកទាទាញគោរអីទៅជាមួយគាត់ទៅហើយដើរទិញជ្រូកទិញមាន់អីហ្នឹងហើយ!

កៈ អូ៎ចុះចឹងសំរាប់ឪពុករបស់មីងគាត់ធ្លាប់ប្រាប់ពីប្រវត្តិកាលគាត់នៅក្មេងទៅមីងអត់?

ខៈ អត់ដែរនិយាយទេឪពុកខ្ញុំមិនដែរនិយាយអីផង។

កៈ ឪពុកចុងអត់ដែរ?

ខៈ អត់ដែរនិយាយទេ។

កៈ ថានៅក្មេងគាត់ធ្លាប់ធ្វើអីគេខ្លះធ្លាប់ធ្វើស្រែរឺក៏ធ្លាប់ធ្វើអីគាត់ធ្លាប់និយាយអត់អត់ណា?

ខៈ គាត់ធ្វើតែស្រែលោកគ្រូគាត់ធ្វើតែស្រែ។

កៈ អូ៎ចុះយាយគាត់ធ្លាប់ប្រាប់ពីប្រវត្តិគាត់កាលនៅក្មេងអីអត់?

ខៈ
ធ្លាប់ប្រាប់ថាជំនាន់ប៉ុលពតពិបាកចេះមួយចុះមួយអីគាត់ប្រាប់តែខ្ញុំមិនចាំទេលោកគ្រូអើ
យ!

កៈ អូ៎ធ្លាប់និយាយដែរហោស?

ខៈ ធ្លាប់និយាយ។

ក៖ ចុះអើយាយតាខាងឪពុកមីងស្គាល់ឈ្មោះគាត់អត់?

ខ៖ យាយតាខាងឪពុកខ្ញុំ។

ក៖ បាទ!

ខ៖ អត់ស្គាល់ផងលោកគ្រូធ្វើការខាងអីដើរសម្ភាស?

ក៖ អូ៎ខ្ញុំធ្វើការខាងអោយសកលវិទ្យាល័យ..?

ខ៖ អាហ្នឹងខាងពុកខាងយើង..។

ក៖ ទាក់ទងពីប្រវត្តិចាស់ៗអីចឹងហាសណាស់?

ខ៖ ប្រវត្តិពីដើមចាស់ៗ។

ក៖ បាទ!

ខ៖ តាខឹមយាយយិន។

ក៖ ហ្នឹងអើខាង..?

ខ៖ ខាងជីតា។

ក៖ ខាងជីតា?

ខ៖ ខាងជីតាឪពុកខ្ញុំ។

ក៖ អូ៎ហ្នឹងឪពុកបង្កើតណេះ?

ខ៖ ចាឪពុកបង្កើត។

ក៖ អូ៎ចុះអើយាយតាខាងម្តាយ?

ខ៖ យាយតាខាងម្តាយមុតសុក។

ក៖ មុតសុកប៉ុន្តែឪពុកម្តាយគាត់ហាស?

ខ៖ ឪពុកម្តាយ..។

ក៖ ឪពុកម្តាយរបស់យាយ?

ខ៖ ឪពុកម្តាយរបស់យាយម៉ែឈ្មោះអីយាយឈ្មោះអីចាំម៉ែម៉ាក់ឯងហ្នឹងហាសឈ្មោះយាយផឹម។

ក៖ យាយផឹមចុះតា?

ខ៖ តាមុតស្លាប់បាត់ហើយ!

ក៖ តាមុតសួរទាំងអស់សួរពីប្រវត្តិទាំងអស់?

ខ៖ សួរទាំងអស់។

ក៖ អូ៎!

ខ៖ ចាំអាណាស្លាប់ហើយក៏គេសួរដែរ។

ក៖ បាទ!

ខ៖ ស្លាប់ហើយមានសួរអីបើស្លាប់ហើយ!

ក៖ ប៉ុន្តែពួកគាត់ពីមុនពួកគាត់នៅណានៅហ្នឹងមែន?

ខ៖ នៅអ៊ីសៀមរាប។

ក៖ អូ៎ចឹងមានន័យថាស្រុកកំណើតយាយនៅខាងសៀមរាប?

ខ៖ ហ្នឹងហើយ!

ក៖ អូ៎ចុះអើមីងមកនៅហ្នឹងអស់រយះពេលប៉ុន្មានឆ្នាំហើយមីង?

ខ៖ តាំងពីជំនាន់ប៉ុលពតណុងមកពីប៉ុលពតមកចិតប្រាំបី។

ក៖ អូ៎ចិតប្រាំបីមកនៅហ្នឹងម៉ង?

ខ៖ ចាំ!

ក៖ អូ៎ទាល់តឡូវអស់សែសិបឆ្នាំជាងហើយណេះមីងណេះ?

ខ៖ ហ្នឹងហើយ!

ក៖ សែសិបមួយឆ្នាំហើយ?

ខ៖ សែសិប។

ក៖ ចឹងមានន័យថាពេលមកហ្នឹងមីងតូចមីងនៅតូចទេណេះមីង?

ខ៖ នៅតូចកំពស់នេះដឹងក្ដីឡើងមកនៅស្រុកហ្នឹង!

ក៖ អូ៎!

ខ៖ ធំតែមីបង។

ក៖ ចុះមីងមានបងប្អូនកូនចៅណាដែរទៅរស់នៅខេត្តផ្សេង?

ខ៖ អត់ផង។

ក៖ ចេញពីហ្នឹងអត់?

ខ៖ អត់ទេ។

ក៖ ទៅសៀមរាប?

ខ៖ មានតែបងប្អូនខាងម៉ែណុងនៅខាងណុង។

ក៖ ខាងយាយហោស?

ខ៖ ខាងសៀមរាបណុងហើយ!

ក៖ ចុះមាននៅខាងភ្នំពេញមានខាងអីផ្សេងៗទេ?

ខ៖ អត់មានទេ។

ក៖ បាទចឹងក្រៅពីហ្នឹងមានតែនៅមណ្ឌលគិរី?

ខ៖ ចាំមានតែនៅកោះញ៉ែកហ្នឹងមណ្ឌលគិរីក៏អត់មានដែរអត់មាន។

ក៖ អូ៎!

ខ៖ គេគ្មានទៅណាមានតែនៅម្ដុំហ្នឹង!

ក៖ ចុះអើមីងមានកូនក្មួយកូនចៅណាដែរទៅធ្វើការក្រៅប្រទេសអត់?

ខ៖ អត់ផងក្មួយ។

ក៖ នៅថៃនៅអីអត់មានទេហេស?

ខ៖ អត់មានទេ។

ក៖ អូ៎បាទមីងចុះអើស្វាមីរបស់មីងឈ្មោះអីគេមីង?

ខ៖ ឈ្មោះស៊ុនសែម។

ក៖ ប៉ុន្ដែឥឡូវគាត់នៅណា?

ខ៖ គាត់នៅជាមួយប្រពន្ធគាត់។

ក៖ អូ៎ចឹងមានន័យថាយើងលែងលះគ្នាហើយហោស?

ខ៖ ខ្ញុំលែងលះគ្នាឡើងជិតដប់ឆ្នាំហើយ!

ក៖ អូ៎!

ខ៖ ប៉ុន្ដែគាត់មកហូបបាយថ្ងៃមិញគាត់មកហ្នឹងទើបទៅទៅបេះព្រីងអោយខ្ញុំហ្នឹង!

ក៖ អូ៎!

ខ៖ លែងដូចជាមិនលែងដឹង។

ក៖ ម៉េចចឹងមីង?

ខ៖
គាត់សុំមកយកខ្ញុំវិញប៉ុន្ដែខ្ញុំអាណិតគេណោះគេយកមានកូនមានចៅហើយគាត់ជឿបងប្អូនគាត់កាលណុងគាត់ជឿបងប្អូនគាត់ពេកមកហ្នឹងមានដាំបាយស៊ីទាំងអស់តែគ្នាចឹងខ្ញុំមកសំរេចចិត្ដថាបានមួយថ្ងៃពីរថ្ងៃមកទៀត។

ក៖ អូ៎!

ខ៖ ឥឡូវឯងគិតអោយវែងឆ្ងាយមុនហ្នឹងថាលែងខ្ញុំតែលែងខ្ញុំអត់យកវិញទេខ្ញុំថាចឹងហាស!

ក៖ បាទមីង!

ខ
គាត់ថាគាត់ត្រូវតែលែងគាត់ថាឥឡូវបើលែងចែកទ្រព្យសម្បត្តិគ្នាទៅខ្ញុំចែកទ្រព្យរបស់គ្នាទៅឥឡូវគាត់មីស្រីហ្នឹងបំផ្លាញអស់ហើយ!

ក៖ អូ៎!

ខ៖ មីស្រីបំផ្លាញជិតរាប់ម៉ឺនហាសក្មួយខ្ញុំចែកអោយហាសគាត់លក់ហាស!

ក៖ បាទមីង!

ខ៖ ឥឡូគាត់...?

ក៖ ចឹងគាត់ស្ដាយក្រោយ?

ខ៖ គាត់ស្ដាយក្រោយគាត់គេសុំខ្ញុំថាឯងអើយខ្ញុំខុសហើយខ្ញុំតាមបងប្អូនចឹងហាស!

ក៖ បាទមីង!

ខ៖
ឥឡូវខ្ញុំសុំយកឯងវិញខ្ញុំថាខ្ញុំយកទៅអត់រួចទេតែរបស់ខ្ញុំចែកអោយទាំងអស់អ្នកឯងបំផ្លាញអស់ហើយមកស៊ីកេរ្ដិ៍ខ្ញុំទៀតខ្ញុំអត់យកវិញទេខ្ញុំថាចឹងហាស!

ក៖ បាទមីង!

ខ៖
ហើយយ៉ាងណាមួយអាណិតដល់គ្នាអ្នកយកគ្នាមានកូនមានចៅដែរនោះហើយយើងប្រលះពីទ្រូងចិត្តគេចិត្តយើង។

ក៖ បាទ!

ខ៖ ចឹងខ្ញុំយល់ចឹងខ្ញុំថាខ្ញុំអត់យកទេខ្ញុំសុខចិត្រាប់អានគ្នាធម្មតា។

ក៖ អូ៎!

ខ៖ រាល់ថ្ងៃហ្នឹងមីចុងមីដើមមកហ្នឹងហូបបាយទើបទៅហ្នឹងមកដាំបាយស៊ីទៅ។

ក៖ ប៉ុន្តែយើងអត់មានគំនុំអី?

ខ៖
អត់មានអីទេមីចុងដើមគ្មានទាស់អីគ្នាទេនិយាយគ្នាធម្មតាជាមួយប្តីហ្នឹងក៏និយាយធម្មតា។

ក៖ អូ៎!

ខ៖ ចឹងមានន័យថាទាំងប្តីប្រពន្ធគាត់មកបាយដែរ?

ខ៖ មកហូបបាយផ្ទះមីង។

ក៖ អូ៎!

ខ៖ ហើយនិយាយគ្នាធម្មតាទៅ។

ក៖ អូ៎!

ខ៖
ពេលខ្ញុំឈឺចឹងទៅគាត់នាំប្តីប្រពន្ធមកមើលខ្ញុំទៅពេលដែរគាត់ឆ្លងទន្លេខ្ញុំនាំកូនឌុបខ្ញុំទៅមើលគាត់ចឹងទៅ។

ក៖ អូ៎!

ខ៖
អត់មានថាទំនាស់ទាស់ទែងគ្នាកាន់គ្នាវណ្ណៈគ្នាអីថាមុខមិនអោយក្រោយមិនមើលអីអីអទ់រាប់រានធម្មតា។

ក៖ ប៉ុន្តែគាត់ឥឡូវគាត់នៅណា?

ខ៖
គាត់នៅថ្នល់ឡានហោសនៅមើលគោអោយប្អូនខ្ញុំអាមួយខ្ញុំថាវាធ្វើជាងម៉ូតូនៅអាកែងរង្វង់មូលផ្ទះពេទ្យសត្វហ្នឹង!

ក៖ បាទ!

ខ៖ អាទិត្យអូនហ្នឹង!

ក៖ អូ៎!

ខ៖ ណុងប្អូនគាត់បង្កើតហើយណុងប្អូនប្តីខ្ញុំបង្កើតហាសមីស្រីហាស!

ក៖ បាទ!

ខ៖ ណុង។

កៈ ចឹងអើមានន័យថាកូនចៅមីងមើលទាំងអស់?

ខៈ មើលទាំងអស់ហើយកូនអត់តាមឪវានៅជាមួយខ្ញុំទាំងអស់។

កៈ រួចចុះគាត់ណោណុងគាត់កូនប៉ុន្មានទៅ?

ខៈ
ទៅលែងពីខ្ញុំទៅទៅយកមីពោធ៍សាត់ណោះយកបានកូនពីរស្រីទាំងពីរមកយកក្រចេះរាល់ថ្ងៃហ្នឹងបានពីរទៀតប្រុសមួយស្រីមួយ។

កៈ នៅក្រចេះ?

ខៈ ចំាយកនៅក្រចេះ។

កៈ អូ៎ឥឡូវហ្នឹងគាត់មកនៅហ្នឹងដែរ?

ខៈ នៅជាប់ៗហ្នឹងក្រចេះហ្នឹង!

កៈ អូ៎!

ខៈ ហ្នឹងហើយ!

កៈ ចឹងមានន័យថាគាត់ចេញពីមីងទៅគាត់យកពីរនាក់ទៀតហើយ?

ខៈ យកពីរ។

កៈ អូ៎!

ខៈ យកបានពីរទៀតចេញពីខ្ញុំទៅ។

កៈ អូ៎ចឹងបាន..?

ខៈ ពេល..។

កៈ ចឹងបានមីងអត់យកវិញណេះ?

ខៈ
អត់យកទេខ្ញុំថាហើយខ្ញុំថាម៉េចបំផ្លាញទ្រព្យរបស់អស់ហើយទើបនឹកឃើញថាខុសពេលដែរភូមិឃុំគេអប់រំថាអោយយកទៅគិតកន្លះខែសិនទៅ
អ្នកឯងអារកាត់ថាលែងខ្ញុំថាមិនលែងអ្នកឯងលែងខ្ញុំលែងដែរទៅឥឡូវមកយកវិញស្រីបោកអស់ខ្ញុំអត់យកទេខ្ញុំនិយាយចឹង
ដល់ពេលខ្ញុំនិយាយចឹងគាត់មានហ៊ានមាត់ណាហើយលួចគេមិនអោយប្រពន្ធដឹងទេលួចគេដែរថាសុំយកខ្ញុំអត់អោយប្រពន្ធដឹងទេតែខ្ញុំគេប្រាប់ប្រពន្ធខ្ញុំមនុស្សខ្ញុំត្រង់។

កៈ បាទ!

ខៈ
ខ្ញុំមិនយកខ្ញុំគេប្រាប់ប្រពន្ធថាមីងវាឯងឈ្មោះគ្នាអីបានឪវាគេមកសុំយកខ្ញុំវិញហើយខ្ញុំថាខ្ញុំអត់យកទេខ្ញុំនិយាយតែត្រង់។

កៈ បាទមីង!

ខៈ ខ្ញុំនិយាយតែត្រង់ប្រាប់ប្រពន្ធថាចុងប្រពន្ធគេមិនដែរខឹងអីខ្ញុំទេខ្ញុំ
និយាយតែត្រង់គាត់ថាបងប្អូនគាត់ញូសញ្ញងយើងគ្របបាយអោយហូបក៏មិនហូបដែរបងប្អូនគេបំបែកបំបាក់យើងហាស!

កៈ បាទ!

ខៈ
គេចាំតែសើចយើងហ្នឹងដល់គេចែកទ្រព្យរបស់ទាំងអស់គោមានចែករទេះម៉ូតូមីងចែកស្រែមីងចែកលក់ទាំងអស់រលីង។

កៈ អូ៎!

ខៈ លក់រលីងមីស្រីណុងបោកអស់មីពោធ៌សាត់ណុងមីដំបូងណុងបោកអស់។

កៈ បាទមីង!

ខៈ
បោកបានកូនមួយយកទៅដល់ធ្វើបាបឯងទៀតបាយមិនបាយទឹកមិនទឹកបានម៉ែក្មេកទេគេមានចិត្តធ៌មហ្នឹងគេអោយមួយលានមករត់មកវិញមក។

កៈ អូ៎!

ខៈ
ខំអីណុងមីណុងធ្វើបាបដើរតែត្រនុយខារ៉ាអូខេត្រឹមៗនេះដើរតែច្រៀងរាំសប្បាយគេដែរគិតឆ្នាំងគិតចានអី។

កៈ តែគេខាងណុងគេចាស់ដែរតើហីមីងណេះ?

ខៈ ទេមីណុងរៀងឆ្នាំដូចខ្ញុំចឹង។

កៈ អូ៎!

ខៈ មីងហ្នឹងគេនៅក្មេងជាងខ្ញុំគេថោះនៅជួរក្រោយចឹងហាសអាអូន។

កៈ អូ៎បាទមីង!

ខៈ ថោះជួរក្រោយខ្ញុំជួរមុន។

កៈ គេប្អូនមួយជួរណេះ?

ខៈ ណុងហើយថោះជួរមុនជួរក្រោយ។

កៈ ចុះមីងអើចឹងមីងកាលជាមួយពូណុងអស់ប៉ុន្មានឆ្នាំហើយមីង?

ខៈ ចូលសាមសិបឆ្នាំជាងហើយការតាំងពីអាយុដប់ប្រាំពីរ។

កៈ ដប់ប្រាំពីរឥឡូវមីងអាយុសែ..?

ខៈ សែប្រាំមួយ។

កៈ សែប្រាំមួយចឹងការអស់ម្ភៃប្រាំបួនឆ្នាំហើយណេះ?

ខៈ ហ្នឹងហើយ!

កៈ អូ៎!

ខៈ ជិតសាមសិបឆ្នាំហើយ!

កៈ
បាទមីងចុះកាលពេលមីងការហ្នឹងមីងដូចជាមីងចិត្តយកខ្លួនឯងរឺមួយក៏ឪពុកម្តាយជាអ្នក..?

ខៈ តាមម៉ែតាមឪ។

កៈ អូ៎ពួកគាត់រៀបចំអោយយើងហោស?

ខ៖ ហ្នឹងហើយម៉ែថាអោយពីណាពីណុងហើយដេកតែយំទៅមិនដឹងថាម៉េច។

ក៖
អូ៎មឹងអាចប្រាប់បើប្រវត្តិខ្លះៗបានទេចុះមឹងគិតថាអើចឹងមឹងអាចប្រាប់ដូចជាប្រវត្តិស្នេហាខ្លះមួយចំនួនបានទេជំនាន់ណុង?

ខ៖ ខ្ញុំអត់ចេះផង។

ក៖ ប៉ុន្តែអើដូចជាមឹងដូចជាមឹងការហើយដំបូងៗជាមួយពូអីចឹងហាសណាស់?

ខ៖ ចា៎!

ក៖ ពេលណុងដូចជាមានអីរឿងអីកើតឡើងអត់មឹង?

ខ៖
អត់ទេអត់ចេះស្រឡាញ់អីគ្នាមុនផងអត់ចេះទាក់ទងអីផងតែម៉ែឪទេចូលសួរម៉ែចឹងទៅម៉ែថាអោយទៅតាមម៉ែ។

ក៖ អូ៎ប៉ុន្តែមឹងធ្លាប់ប្រាប់ពីមុនថាអើយើងអត់គេងជាមួយគ្នាយើងរត់ចេញម៉េចហោសមឹង?

ខ៖
អូ៎អាហ្នឹងខ្ញុំនៅឆោតណុងខ្ញុំមានដឹងអីណាថាម៉ែអោយទៅគេណុងខ្ញុំដឹងតែយំណុងហើយដល់ហើយ ដល់ការហ្នឹងមិនមិនដឹងថាគេធ្វើម៉េចៗអត់ដឹងដឹងតែរត់ចេញពីក្នុងណុងយំណុង។

ក៖ អូ៎!

ខ៖
មិនដឹងថាម៉េចផងហើយម៉ែចេះតែមួលក្លេចៗខងអុំដឹងមួលក្លេចដេកវិញហោសជួនកាលចឹងទៅខ្លាចគេខ្លាំងទៅរត់ទៅបត់ជើងដីមិនឈឺក៏ទៅសំងំអង្គុយសំកុកហ្នឹងដីចឹងទៅមិនដឹងថាម៉េច។

ក៖ អូ៎បាទមឹងប៉ុន្តែខាងពូអីគាត់អត់អីទេណេះគាត់អត់ថាអី?

ខ៖
គាត់ថាតើគាត់ថាមកប្រាប់ម៉ែខ្ញុំថាសុំម៉ែខ្ញុំមកផ្ទះម៉ែឪគេវិញដូចថាយើងអត់ចុះដំនេកជាមួយគេនិយាយខ្ញុំអត់ចេះទៅថាអត់ដឹងអីហោស!

ក៖ បាទមឹង!

ខ៖ បើចាស់ពីដើមគេថាយើងអត់ចុះដំនេកជាមួយគេណុងហើយ!

ក៖ អូ៎!

ខ៖ បើយើងអត់ដឹងហោស!

ក៖ បាទមឹងបាទ!

ខ៖
អត់ដឹងអីក្មេងចឹងបានមឹងថាមឹងនៅក្មេងគ្មានដឹងអីផងហ្នឹងគ្រាន់តែគ្រប់ការភ្លាមខ្មោចម៉ែក្មេកណុងចូលដណ្តឹងភ្លាមដណ្តឹងមានយូរអីការភ្លាមណុង។

ក៖ អូ៎!

ខ៖
មានអោយទៅគ្រប់ការអោយបានមួយឆ្នាំផងណុងគ្រាន់តែមើលផ្លាច់សាច់ឈាមប្លែកម៉ែសួរហើយម៉ែក្មេកខ្ញុំចេះតែសួរមួយថ្ងៃពីរបីដងសួរម៉ែខ្ញុំហ្នឹង!

ក៖ បាទមីង!

ខ៖
ហើយម៉ែចេះតែថាមិនទាន់គ្រប់ការទេអ្នកអោយទាល់ម៉ែប្លែកសាច់ប្លែកឈាមណុងបានគាត់សួរបងខ្ញុំថាគ្រប់ការនៅបានបងខ្ញុំប្រាប់ថាគ្រប់ហើយចឹងគាត់យាយហ្នឹងម៉ែក្មេកខ្ញុំទៅចូលសួរម៉ែខ្ញុំទៅ។

ក៖ អូ៎!

ខ៖
មានទាន់ទៅដឹងអីមែនណុងនៅលោតទឹករត់លេងមិនដឹងអីផងមិនដឹងខ្យល់អីបន្តិចផងណុង។

ក៖
បាទចុះអើមីងកាលជំនាន់មីងការហ្នឹងដូចជាពូមានបង្គាប់ថ្លៃទឹកដោះហើយមីងអត់ថ្លៃបណ្ណាការហាស?

ខ៖ ដូចជាបង្គាប់មិនបង្គាប់ម៉ែខ្ញុំមិនសូវដឹងដែរ។

ក៖ កាលណុងមានអត់យាយ?

ខ៖ បង្គាប់បានបីពាន់ណុង។

ក៖ បីពាន់លុយខ្មែរយើង?

ខ៖ បីពាន់ពីដើមណុង។

ក៖ ប៉ុន្តែបីពាន់យើងអាចធ្វើជាការបានហើយណេះ?

ខ៖
ការបានលោកគ្រូតែការជំនាន់ណុងមែនមានតុមានអីទេអានេះអាឈើយើងនេះធ្វើរោងប្រកស្បូវហើយហ្នឹងក្រាលលែងអាហ្នឹងក្រាលអាប្រាំដប់ប្រាំហ្នឹងរៀបចានតាជាត់ៗហ្នឹង!

ក៖ បាទមីង!

ខ៖ ធ្វើតុអង្គុយឬស្សី។

ក៖ អូ៎!

ខ៖ ប្រកស្បូវ។

ក៖ ប៉ុន្តែម្ហូបអាហារគេដូចតែយើងដែរឬមួយក៏ម៉េច?

ខ៖ ម្ហូបអាហារដូចតែយើងសាច់ជ្រូកសាច់គោស្លដូចគ្នា។

ក៖ អូ៎!

ខ៖ ញ៉ាំអីម្លូរខ្ទីសម្លរអីដូចគ្នាចឹង។

ក៖ កាលជំនាន់មីងការហ្នឹងគេចាយលុយនៅ?

ខ៖ ចាយលុយមួយកាក់មួយសេនហ្នឹង!

ក៖ អូ៎ប៉ុន្តែគេចងដៃចងអីយើងទៅ?

ខ៖ គេចងដៃគូចដៃចងដៃ។

ក៖ ប៉ុន្តែកាលជំនាន់ណុងគេ..?

ខ៖ មួយពាន់ពីរពាន់។

ក៖ គេចងជាអង្គរអីដែរតើហី?

ខ៖ អត់ទេចងតែលុយអត់មានអង្គរស្រូវអីអត់មានទេ។

ក៖ អូ៎!

ខ៖ ចងតែលុយ។

ក៖ មីងការឆ្នាំប៉ែត្រជាងហើយណេះមីងណេះកៅជាងហើយ?

ខ៖
ដឹងទេព្រោះខ្ញុំមិនសូវចាំព្រោះខ្ញុំចាយលុយមួយកាក់មួយសេនណុងនៅចាយនៅឡើយណុង។

ក៖ អូ៎!

ខ៖ ការណុង។

ក៖ បាទមីងចុះអើមីងទាល់ឥឡូវមីងមានកូនប៉ុន្មាននាក់ហើយមីង?

ខ៖ ខ្ញុំមានតែបី។

ក៖ បីនាក់ណេះមីងណេះ?

ខ៖ ហ្អឹងហើយ!

ក៖ ចុះចឹង..?

ខ៖ តែខ្ញុំរៀបចំអស់មួយនៅតែពីរ។

ក៖ អូ៎ចុះអើស្រីទាំងបីណេះមីងណេះ?

ខ៖ ស្រីទាំងបី។

ក៖ ចុះអើកូនបងគាត់អាយុប៉ុន្មានហើយទាល់ឥឡូវ?

ខ៖ កូនបងមីអូនវាចូលម្ភៃប្រាំបួនហើយឆ្នាំមមែ។

ក៖ ម្ភៃប្រាំបួនណេះមីងណេះ?

ខ៖ ហ្អឹងហើយ!

ក៖ អូ៎!

ខ៖ មកបន្ទាប់មកឆ្នាំរកា។

ក៖ ចុះកូនពៅ?

ខ៖ កូនពៅឆ្នាំកោរ។

ក៖ អូ៎ចុះកូនបងគាត់ធ្វើអីគេទៅមីងឥឡូវ?

ខ៖
មានធ្វើអីទេមានដូចថាគេធ្វើថៃឈ្នួលដូចថាគេភ្ជួរទៅស៊ីខែចឹងទៅទៅធ្វើការខែគេទៅក្អួយ
អោយមានធ្វើអី។

ក៖ អូ៎ទៅធ្វើនៅដល់ណាទៅ?

ខ៖ ត្រឹមខេត្តភ្នំពេញ។

កៈ អូ៎ចឹងបើគេហៅទៅចឹងយើងទៅៗ?

ខៈ
ហ្នឹងហើយគេគេហៅទៅទៅៗមួយខែមួយរយហាចឹងទៅមួយរយអីចឹងទៅចេះតែទៅទៅក្អួយអើយមិនដឹងធ្វើអីធ្វើស្រែហើយហើយធ្វើតែស្រែហ្នឹងដើរធ្វើតែប៉ុណ្ណឹង!

កៈ អូ៎ប៉ុន្តែឥឡូវគាត់មកវិញគាត់អត់ទៅទេ?

ខៈ អត់ទៅទេបើកូរ៉ូណានៅមិនហ៊ានអោយកូនទៅណា។

កៈ អូ៎!

ខៈ មិនហ៊ានអោយទៅទៀតទេ។

កៈ ចុះកូនទីពីរទៅដែរ?

ខៈ កូនទីពីរនៅមើលខ្ញុំមានហ៊ានទៅចោលទេទៅបានតែមីបង។

កៈ អូ៎!

ខៈ នៅមើលម្តាយផ្ទះ។

កៈ ចឹងមានន័យថាកូនបងទៅរកលុយនៅណុងទៅ?

ខៈ
ហ្នឹងហើយកូនបងទៅរកទៅនៅមីទីពីរមើលខ្ញុំទៅព្រោះកាលនៅជុំបងប្អូនបីនាក់ចឹងគេទៅពីរគេនៅមួយមើលខ្ញុំចឹងទៅ។

កៈ អូ៎បាទមីង!

ខៈ ហ្នឹងហើយ!

ក ដល់ពេលឥឡូវអើកូនពៅការបាត់ទៅ?

ខៈ ការគេបាត់ទៅនៅមួយ។

កៈ នៅមួយនៅហ្នឹង?

ខៈ
ហ្នឹងហើយមើលខ្ញុំមីកណ្តាលវាអត់សូវសំដីសូវមាត់ចឹងមីបងវាមាត់ដូចមីប្អូនចឹងទៅគេដើរឆ្ងាយ។

កៈ បាទ!

ខៈ ចឹងទុកមីមិនសូវចេះមាត់នៅមើលមីង។

កៈ បាទមីងចុះអើប្អូនគាត់ការទៅគាត់ទៅនៅណាមីង?

ខៈ នៅខាងឪក្មេកគេគេចែកដីសែចផ្ទះស្រាប់។

កៈ អូ៎គេធូរហលយមីងចឹង?

ខៈ អូ៎គេការហើយគេធូរមានពិបាកអីឪគេស្រឡាញ់ចង់ងាប់ហើយម៉ែក្មេកគេ។

កៈ អូ៎គាត់នៅណុងគាត់ធ្វើអីគេជាមួយប្តីគាត់?

ខៈ លក់ឥវ៉ាន់ចាប់ហ្វ៊ុយហ្នឹងហើយធ្វើស្រែ។

កៈ អូ៎បាទមីងចុះមីងធ្លាប់បានរៀនអត់មីង?

ខ៖ មីងគ្មានចេះទេគ្មានបានរៀនទេក្មួយអើយ!

ក៖ អត់ដែរបានរៀនទេ?

ខ៖
អត់ដែរបានរៀនសូត្រទេតែនខ្វាក់ក៏មិនចេះចឹងបានគេថាដាក់កន្លែងហ្នឹងមីនហាសគេថាមីនក៏មីងមិនដឹងដែរមីងនៅតែទៅហើយអត់ដឹងអានខ្វាក់អីទេ
មីងអត់ចេះម៉ងមីងនិយាយថាមីងអត់បានរៀនអត់ចេះទេ។

ក៖ អ៎ូ!

ខ៖
ចឹងបានរាល់ថ្ងៃគេតេមកអីគេស្អីដាក់ស្អីមកមីងមិនចេះទេអោយតែកូនមើលទៅមីងអត់ចេះផងណុង។

ក៖ អ៎ូបាទមីងចឹងភាសាអីក៏មីងអត់ចេះដែរណេះ?

ខ៖ អត់ចេះទេ។

ក៖ ចេះតែខ្មែរ?

ខ៖ ចេះតែខ្មែរ។

ក៖ អ៎ូគីឡូជំនាន់ណុងគេអោយរៀនភាសាបារាំងអីចឹងហាសណាស់មីង?

ខ៖
អត់ទេចឹងបានខ្ញុំស្តាយខ្លួនលោកគ្រូអើយថាស្តាយខ្លួនណាស់ចេះតែនិយាយកូនក្មួយក្មួយអើយប្រឹងរៀនទៅស្តាយខ្លួនដូចអ៊ុំ អ៊ុំដូចមនុស្សខ្វាក់ភ្នែកហើយណេះ។

ក៖ អ៎ូបាទ!

ខ៖ ជួយរកគោរាំរាបាត់មីមេចាស់ហោសយកមួកទៅអោយគេផងកុំអោយអានោះរអ៊ូអាណុងទៅទាក់មាន់មិនដឹងទៅដល់ណាទេទាក់មាន់ស្អីទៅយកមាន់ពូជសំបូររាទៅនៅអ៊ីត្រោយម្ខាងហោសហ៎គ្រាន់តែម្លូទាយកដែរ។

ក៖ ចុះរួចឹងមីងធ្លាប់មានមិត្តភក្តិស្និទ្ធស្នាលដែរធំធាត់មកជាមួយគ្នាអត់មីងកាលនៅពីតូច?

ខ៖ មានតើមិត្តភក្តិខ្ញុំនៅទីបួនណុងទាំងអស់។

ក៖ ចឹងហោស?

ខ៖ ចាំ!

ក៖ មីងមានច្រើនហោស?

ខ៖ មានច្រើនដើរមើលក្របីឃ្វាលគោអីជាមួយគ្នាចឹងមិត្តភក្តិខ្ញុំបីបួននាក់។

ក៖ អ៎ូ!

ខ៖ ហ្នឹងហើយ!

ក៖ ប៉ុន្តែឥឡូវគាត់នៅណុងតើហី?

ខ៖ គេនៅផ្ទះផ្សេងៗពីខ្ញុំហើយណុងផ្ទះគេនៅម្តុំណុងទៅមុខៗ។

ក៖ មានគ្រួសារមានអីចឹងទៅណេះមីងណេះ?

ខ៖ ចាំដល់មានគ្រួសារទៅគេនៅបែកអស់ទៅ។

ក៖ អូ៎បាទមីងប៉ុន្តែមីងធ្លាប់ធ្វើស្រែចំការណេះមីងណេះ?

ខ៖ ខ្ញុំធ្វើស្រែចំការ។

ក៖ មីងធ្លាប់ចំការអត់?

ខ៖ ធ្វើចំការដែរ។

ក៖ ភាគច្រើននៅចំការមីងធ្វើអីគេខ្លះទៅ?

ខ៖ ដាំតែត្រសក់ននោងល្ពៅ។

ក៖ ប៉ុន្តែនៅហ្នឹងណេះមីងណេះ?

ខ៖ ចាំតែឥឡូវឈប់ដាំហើយអូន។

ក៖ ដីលក់អោយគេទៅ?

ខ៖
ដីលក់អោយគេទៅបើគេមួយគេចូលមកពីរគេចូលមកតាំងពីដីធំមកដល់ដីប្រាំប្រាំមួយម៉ែត្រលក់ចោលតែម៉ងទៅ។

ក៖ អូ៎!

ខ៖
គេចូលទៅមីងមិនដែរមាត់មួយម៉ាត់ទេបើយើងកណ្តាលគេអមសងខាងគេឃ្វាលចូលទៅអាហ្នឹងចូលមកកំពិតមីងនៅកណ្តាល។

ក៖ អើម៉េចចឹងមីង?

ខ៖
មីងអត់មាត់មួយម៉ាត់ទេមីងលក់អោយគេតែម៉ងទៅមីងមួយម៉ាត់មីងមិនមាត់ថាដាក់ទំនាយពីណាក៏មិនដាក់ដែរអោយគេទូលទៅ យើងដឹងតើដឹងចំនួនដីយើងថាប៉ុន្មានៗដឹងតើ!

ក៖ អូ៎!

ខ៖
ដីជំនាន់ណុងតាំងពីជំនាន់ក្រុមសាមគ្គីគេចែកក្បាលដប់ពីរម៉ែត្រដល់យូរទៅគេចូលទៅពីជើងចូលបន្តិចពីត្បូងចូលបន្តិចមីងកណ្តាលនៅសល់តែប្រាំមួយម៉ែត្រទុកធ្វើអីក្បួយ។

ក៖ អូ៎បាទមីង!

ខ៖ លក់ក្រវ៉ាត់ចោលតែម៉ងទៅគេអ្នកចង់បានខ្ញុំថាអោយទទួលទៅខ្ញុំលក់ទៅ។

ក៖ អូ៎!

ខ៖
ឥឡូវធ្វើតែស្រែទេក្មួយអើយបើដីចំការលក់អោយគេអស់ហើយធ្វើតែស្រែទេភាគច្រើនមីងធ្វើស្រែប្រាំងរឺមួយស្រែវស្សាមីង?

ខ៖ ធ្វើស្រែវស្សា។

ក៖ ដោយសារនៅហ្នឹងអត់សូវមានទឹកណេះមីង?

ខ៖ ហ្នឹងហើយ!

ក៖ គេអត់ធ្វើ?

ខ៖ត្រពាំងខ្ញុំបើសិនជាថាធ្វើស្រែប្រាំងក៏បានដែរត្រពាំងពីរតែវាអត់មានរបងអត់មានអីចឹងវាពិបាកយាមគោយាមក្របីកូនសុទ្ធតែស្រីទៅមើលណាសុទ្ធតែស្រីហោស!

ក៖ បាទមីង!

ខ៖ ចឹងមីងធ្វើតែប្រាំងមីងធ្វើតែវស្សាទៅ។

ក៖ តែឆ្ងាយហោសមីង?

ខ៖ ឆ្ងាយជិះអើជិះឡានជិះម៉ូតូមួយស្របកដែរ។

ក៖ ដល់ណាមីង?

ខ៖ ជិតកន្លែងផ្ទះប្តីមីងនៅដែរណុងជិះម៉ូតូមិនបានដប់នាទីផងហ្នឹង!

ក៖ អូ៎!

ខ៖ មកដល់ស្រែហ្នឹង!

ក៖ បាទមីងបាទ!

ខ៖ ហើយស្រែមីងជាប់ហ្នឹងផ្លូវហ្នឹង!

ក៖ បាទមីងស្រួល?

ខ៖ ស្រួលជាប់ផ្លូវហ្នឹង!

ក៖ ប៉ុន្តែភាគច្រើនជាទូទៅនៅស្រែមីងធ្វើអីគេខ្លះមីង?

ខ៖ ចាំ!

ក៖ ភាគច្រើននៅស្រែមីងធ្វើអីគេខ្លះទៅដកស្ទូងភ្ជួររាស់អីចឹងណេះមីងណេះ?

ខ៖ ខែហៅអាត្រាក់គេទៅភ្ជួរព្រុះចោល។

ក៖ អូ៎!

ខ៖
មិនដែរស្ទូងផងពីមុនស្ទូងប៉ុន្មានឥឡូវគេគ្មានយកអីស្ទូងទេឥឡូវគេព្រុះចោលគ្នាចឹងព្រុះដូចគេទៅ។

ក៖
បាទមីងចុះមីងគិតថាចឹងអើតាំងពីក្មេងរហូតមកដល់ការងារអីគេខ្លះដែរមីងធ្លាប់ធ្វើមីង?

ខ៖ មីងទៅស្ទូងទៅដកស្រូវស្រែចំការដើរស៊ីឈ្នួលគេទៅមានគេជួលដើរស៊ីឈ្នួលគេទៅ។

ក៖ អូ៎ប៉ុន្តែអើមីងធ្លាប់លក់ដូរអត់មីង?

ខ៖អត់ផង។

ក៖ បើកអាជីវកម្មអីក៏មីងអត់ដែលដែរ?

ខ៖ អត់ដែរទេ។

ក៖
អូ៎បាទចុះមីងគិតថាជីវិតរបស់មីងមានការផ្លាស់ប្តូរអីមីងកាលពីក្មេងរហូតមកដល់ឥឡូវការមីងនៅជាមួយឪពុកម្តាយហើយហ្នឹងមីងមានក្រុមគ្រួសារមានការផ្លាស់ប្តូរអីគេខ្លះទៅមីង?

ខ៖
ផ្លាស់ប្តូរយើងចេះគិតខ្លួនយើងពិបាកស្រណុកខ្វះចាយខ្វះអីគិតគំនិតលើយើងទាំងអស់បែកពីម៉ែមក។

ក៖ អូ៎មានន័យថាកាលយើង...?

ខ៖ ការពីរនាក់ប្តីប្រពន្ធណុងតស៊ូធ្វើស្រែធ្វើចំការហ្នឹងទៅ។

ក៖ បាទមីងចឹងមានន័យថាកាលមីងនៅជាមួយឪពុកម្តាយអើ...?

ខ៖ ពឹងផ្អែកលើឪពុកម្តាយហូបចុក។

ក៖ បាទមីងដល់ពេលយើងមកមានក្រុមគ្រួសារមកយើង..?

ខ៖
យើងបែកគំនិតខ្លួនយើងហូបចុកអីដូចជាអំបិលប្រហុកប៊ីចេងអីដើរគំនិតសំលៀកបំពាក់អីកូនចៅយើងចុងផ្តើមគំនិតខ្លួនឯងទាំងអស់។

ក៖ អូ៎បាទមីងទាល់តឡូវនៅតែមីងអើ..?

ខ៖ ហ្នឹងហើយ!

ក៖ ដោយសារពួកគាត់ទាំងអស់នៅបន្ទុកលើមីងនៅឡើយណេះមីងណេះ?

ខ៖ នៅបន្ទុកមីងនៅឡើយហ្នឹងហើយ!

ក៖ អូ៎!

ខ៖
កូនទៅធ្វើការបានមកទៅប្រគល់លុយអោយម្តាយទៅម្តាយចាត់ចែងលើអីស្រេចតែម៉ែទៅ។

ក៖ អូ៎បាទមីងចុះមីងគិតថាម្ហូបអីដែរមីងចូលចិត្តហូបមីង?

ខ៖ ខ្ញុំស្អីក៏ហូបដែរមិនតមផង។

ក៖ អត់ទេពេលខ្លះម្ហូបដែរយើងឃ្លានហាសយើងគិតថាយើងចូលចិត្តម៉ងហាស?

ខ៖ ម្ហូបដែរចូលចិត្តម៉ងគឺមាន់ដុតម៉ងបបួលតែកូនដុតស្ងោរជ្រកក៏មិនសូវដែរ។

ក៖
អូ៎បាទមីងចុះមីងគិតថាចឹងដូចជាចឹងកាលមីងនៅក្មេងមីងធ្លាប់លេងល្បែងប្រជាប្រិយ៍អីអត់មីងដូច...?

ខ៖ អត់។

ក៖ លក្ខណៈថាបោះអង្គុញចោលឈូង?

ខ៖ អូ៎លេងខែបុណ្យទានចូលឆ្នាំ។

ក៖ នៅហ្នឹងហោសមីងហោស?

ខ៖ ចាំលេងពីមុនលេងហាស!

ក៖ បាទមីង!

ខ៖ តែតឡូវអត់ដែរលេងទេ។

ក៖ តឡូវក្មេងៗលែងមាននរណាគេលេង?

ខ៖ អត់លេងដូចជំនាន់មុនទេ។

ក៖ បាទមីង!

ខ៖ លេងបោះឈូងលេងអង្គុញ លេងទាញព្រាត់លេងច្រកបាំងវត់។

ក៖ អូ៎បាទមីងចុះមីងគិតថារាំច្រៀងមីងចូលចិត្តអត់?

ខ៖ អូ៎រឿងរាំច្រៀងពីក្រមុំដាច់ខាតអត់អោយចុះពីលើផ្ទះទេ។

ក៖ អូ៎!

ខ៖ នៅតែលើផ្ទះហ្នឹងតែរនាបស្រីបតិចហ្នឹងរកប្រន្ទួងរកពូថៅហើយ!

ក៖ អូ៎!

ខ៖ មិនដែរអោយបានដើរលេងសប្បាយទេ។

ក៖ យើងចង់ដែរប៉ុន្តែ...?

ខ៖ ចង់ពីរនាក់បងខ្ញុំណុងលួចទំលាក់ខោអាវមកដីក៏មានដែរលួចបានម្តងលួចម៉ែទៅមើលគេថាគេមកពីខេត្តមណ្ឌលគិរីយើងពីដើមអត់ទាន់ឃើញគេការគេមកពីខេត្តមណ្ឌលគិរីហោស!

ក៖ បាទមីង!

ខ៖ ម៉ែខ្ញុំទៅមើលគេគាត់អត់អោយទៅពីរនាក់បងប្អូនទំលាក់ខោតាមប្រហោងរនាបហើយចុះមកស្លៀកពាក់អោយគ្រងរត់ព្រុចបាត់មកដល់ផ្ទះម៉ែដេរមករែកទឹកពេញៗពាងមួយសន្ទះហើយម៉ែដេរទៀត ចេះតែមិនមាត់ទៅលួចចង់មើលគេហោស!

ក៖ បាទមីង!

ខ៖ កំរបានដើរហាសនៅពីក្រមុំម៉ែមិនដែរដើរទេ។

ក៖ អូ៎ដោយសារគេថាស្អីគេដូចយាយ..?

ខ៖ ជំនាន់ខ្មែរក្រហម។

ក៖ បាទ!

ខ៖ ម៉ែថាខ្លាច។

ក៖ ដោយសារគេថាចាស់ជំនាន់ណុងគេអត់អោយក្មេងស្រីដើរទៅណាចឹងហាសណេះ?

ខ៖ ហ្នឹងហើយគ្រប់ពេញលក្ខណៈស្រីហើយជំនាន់ណុងនោះមិនងាយទេ។

ក៖ ចឹងមានន័យថាល្ខោនយីកេអាយ៉ៃអីក៏មីងអត់ដែរបានទៅមើលដែរ?

ខ៖ ថាកុនគេដាក់អីវត្តសុំក៏មិនអោយទៅដែរដេកយំពីរនាក់បងប្អូនដាក់គ្នាណុងគាត់មិនអោយដើរតែម៉ង។

ក៖ អូ៎!

ខ៖ មិនអោយទេ។

ក៖ បាទមីងប៉ុន្តែដូចចម៍មមីងឥឡូវមីងស្តាប់ដែរតើមីងហេស?

ខ៖ មីងចេះដែរតើមីងទីសុំសិល្បីរៀនផ៍មសុំតាមយាយៗចេះខ្លះៗ។

ក៖ អូ៎!

ខ៖ តែផ៍មប្រែទេមីងអត់ចេះប្រែ។

ក៖ បាទមីងបាទ!

ខ៖ បើផ៍មស្លូត្រជាមួយយាយតាមីងចេះ។

ក៖ អូ៎!

ខ៖ ខ្លះៗដែរថ្ងៃសុំសិល្បីទៅស្លូត្រជាមួយតាៗយាយៗទៅ។

ក៖
បាទមីងបាទចុះមីងគិតថាមីងមាននរណាគេមួយនៅក្នុងក្រុមគ្រួសារមីងចេះលេងឧបករណ៍ភ្លេងទេមីង?

ខ៖ អត់ផង។

ក៖ កូនក្មួយកូនចៅអីលក្ខណ:ភ្លេងសៀមភ្លេងខ្មែរអី?

ខ៖ ភ្លេងខ្មែរមានតែប្អូនថ្លៃខ្ញុំបើក្នុងក្រុមគ្រួសារខ្ញុំអត់មានទេ។

ក៖ អូ៎!

ខ៖ បើប្អូនថ្លៃខ្ញុំលេងភ្លេងខ្មែរ។

ក៖
បាទមីងបាទចុះមីងគិតថាផ្ទះរបស់មីងមានលក្ខណ:បែបណាមីងកាលពីមីងនៅជាមួយឪពុកម្ដាយមីងហាស?

ខ៖
នៅឪពុកម្ដាយខ្ញុំខ្ញុំការហើយខ្ញុំបែកជំនាន់ណុងខ្ញុំធ្វើនេះកាប់កូនឈើប៉ុនៗហ្នឹងធ្វើរនួតហើយវ៉ៃរនាបចឹងទៅហើយប្រកស្លូវទៅ
ហើយអារងរបាំអីក៍វ៉ៃតែអាឈើប៉ុនៗហ្នឹងដែរគ្មានអីអារទេ។

ក៖ អូ៎!

ខ៖ វ៉ៃធ្វើកូនខ្ទមតូចមួយទៅនៅបែកពីម៉ែពីឪការហើយ!

ក៖ អូ៎បាទមីងដល់ពេលមីងចុះពេលពីមុនហ្នឹងពីមុនមីងនៅជាមួយឪពុកម្ដាយផ្ទះម៉េចទៅ?

ខ៖ ខ្ញុំនៅបែកពីម៉ែណុងហើយ!

ក៖ អត់ទេកាលនៅក្មេងៗហាសមីង?

ខ៖ អូ៎នៅក្មេងៗនៅបន្ទុកជាមួយម៉ែមាននៅណា។

ក៖ ប៉ុន្តែផ្ទះយើងម៉េចទៅមីង?

ខ៖ ផ្ទះក៍លាក់ដូចគ្នាលាក់ដូចខ្ញុំនិយាយចឹងដូចចឹងគល់..។

ក៖ ផ្ទះយាយនៅណោះហោស?

ខ៖
ចាំហ្នងហើយដូចថាលាក់វ៉ៃតែសំបកចេញទៅអាគល់ប៉ុនៗហ្នឹងមករៀបវាជារនួតចឹងទៅហើយអាលើហ្នឹងឬស្សីទៅ។

កៈ អូ៎បាទ!

ខៈ ប្រកស្បូវទៅបាំងជញ្ជាំងបន្តាំទៅ។

កៈ អូ៎!

ខៈ ហ្នឹងខ្ញុំនៅជាមួយម៉ែខ្ញុំដល់បែកមកក៏ឃើញចឹងដែរបែកពីម៉ែហោស!

កៈ មីងមកធ្វើផ្ទះចុះផ្ទះហ្នឹងមីង?

ខៈ ផ្ទះហ្នឹងខ្ញុំបែកម៉ែខ្ញុំមកធ្វើពីរនាក់ប្តីប្រពន្ធគត់ផ្ទះហ្នឹងហាស!

កៈ អូ៎យើងរួមផ្សំទៅល្មមបានប៉ុណ្ណឹងហោសមីងណេះ?

ខៈ
ចាំមួយឆ្នាំផ្សំបានមួយគិបកាលណាផ្សំបានច្រើនតិចចូលបានប្រាំគិបទៅហើយសសរណុងសុទ្ធតែជួលគេអារជួលគេដឹក។

កៈ អូ៎!

ខៈ ជំនាន់ណុងរកគ្នាបានហាសអូន។

កៈ បាទមីងបាទ!

ខៈ រកគ្នាដឹករទេះគោ។

កៈ អូ៎!

ខៈ ហើយរកគេមកជួលអារជាឈើជ្រុងនៅផ្ទះយើងមក។

កៈ ចេះតែសន្សំៗទៅនេះមីង?

ខៈ ចេះតែសន្សំៗល្មមបានប៉ុណ្ណឹង!

កៈ
បាទមីងបាទចុះមីងគិតថាផ្ទះរបស់មីងហ្នឹងគេប្រើឧបករណ៍អីគេខ្លះមីងសំរាប់ធ្វើកាលជំនាន់ណុងមីង?

ខៈ ម៉ាជំនាន់ណុងគេប្រើតែរណាដែកឈូកដៃយើងហ្នឹង!

កៈ អូ៎!

ខៈ ដែកឈូសដៃហើយរណាអារដៃ។

កៈ បាទមីងប៉ុន្តែអើដំបូលប្រកអីគេមីងប្រកក្បឿង?

ខៈ ដំបូលប្រកដែក។

កៈ អូ៎សង្កសីហោស?

ខៈ សង្កសីចាំ!

កៈ អូ៎អើដូចជាមាននរណាគេមួយនៅក្នុងក្រុមគ្រួសារមីងចេះធ្វើផ្ទះអត់ចឹងមីង?

ខៈ ក្រុមគ្រួសារខ្ញុំ។

កៈ បងប្អូនកូនក្មួយមីងអីចឹងហាសណាស់?

ខៈ ចេះតែបងថ្លៃខ្ញុំបើថាកូនក្មួយបងប្អូនខ្ញុំគ្មានពីណាចេះផង។

ក៖ អូ៎បាទមីងចុះមីងគិតថាអើឪពុកម្ដាយរបស់មីងធ្លាប់បង្រៀនពីជំនាញអីទៅមីងអត់?

ខ៖ អត់ធ្វើតែស្រែបានប្ដីឡើងខ្ញុំធ្វើតែស្រែ។

ក៖ ចឹងមីងធ្វើតែស្រែរហូតហោសមីង?

ខ៖ ធ្វើតែស្រែម៉ែធ្វើនំដូចថាវេចនំកំប៉េកកំប៉ុកដូចជាអន្សមជ្រូក
អន្សមចេកនំបញ្ចុះអីហ្នឹងដើរលក់តាមផ្ទះ។

ក៖ អូ៎!

ខ៖ ហ្នឹងម៉ែអោយខ្ញុំទូលដើរលក់តាមផ្ទះចឹងទៅ។

ក៖ តែមីងចេះធ្វើដែរ?

ខ៖ ធ្វើជាមួយម៉ែ។

ក៖ អូ៎!

ខ៖ ហើយដើរលក់ទៅ។

ក៖ ជាទូទៅយើងធ្វើអីខ្លះមីង?

ខ៖ ធ្វើ..។

ក៖ ធ្វើអន្សម?

ខ៖ ធ្វើអន្សមចេក អន្សមជ្រូក នំបញ្ចុះភាគច្រើននំបញ្ចុះដើរលក់ព្រឹកឡើង។

ក៖ អូ៎បាទមីងចុះមីងគិតថាវេញវល្លិ៍ កូរស្ករ ធ្វើកន្ទេលអីមីងចេះអត់?

ខ៖ អត់ផង។

ក៖ ឪពុកម្ដាយក៏អត់ចេះដែរណេះមីងណេះ?

ខ៖ ម៉ែខ្ញុំចេះខ្ញុំអត់ចេះ។

ក៖ អូ៎ទៅគាត់អត់ដែរបង្រៀនទេណេះ?

ខ៖ នៅហ្នឹងវាក្រក្ដោតបើម៉ែក៏មិនអោយរៀនដែរលោកគ្រូម៉ែក៏មិនអោយរៀនដែរ។

ក៖ អូ៎!

ខ៖ ម៉ែក៏យាយមិនអោយរៀនដែរនៅស្រុកណុង។

ក៖ បាទ!

ខ៖ អោយដើរឃ្វាលគោ ក្របី។

ក៖ អូ៎ចឹងទៅឃ្វាលគោហ្នឹងក្របី?

ខ៖ ចាំ!

ក៖
ចុះមីងអាចប្រាប់ពីការលំបាកហើយពីជំនាន់មីងចឹងមីងកើតនៅក្នុងប៉ុលពតម៉ងហោសមីង?

ខ៖
ហ្នឹងហើយខ្ញុំកើតប៉ុលពតបើម៉ែថាបីទទឹងរត់ឆ្លងគ្រាប់ណាណើគាត់ធ្លាប់និយាយប្រាប់ហោសខ្ញុំអត់ដឹងដែរ។

ក៖ ប៉ុន្តែមីងអត់ដឹងទេ?

ខ៖
អត់ដឹងទេម៉ែគាត់និយាយក៏គ្រាប់អីណេះមីរីវៗជិតខ្លួនកូនណុងម៉ែរុះដីខ្សាច់លើកូនអស់ហើយ!

ក៖ អូ៎!

ខ៖ យើងនៅបីទទឹងនៅបៅដោះម៉ែអត់ដឹង។

ក៖ ទាល់តែពេលណាបានមីងចាប់ផ្តើមដឹងមីង?

ខ៖ ទាល់តែ..។

ក៖ បែកហើយ?

ខ៖ ទាល់តែខ្ញុំដឹងក្តីមកម៉ែនិយាយប្រាប់ទៅ។

ក៖ ប៉ុន្តែទាល់បែកហើយបានមីងចាប់ផ្តើមដឹងហីមីងណេះ?

ខ៖ ហ្នឹងហើយ!

ក៖ ឆ្នាំប៉ៃត្រជាងហេស?

ខ៖ ប៉ៃត្រជាងហើយយ៉ាងបានដឹងម៉ែនិយាយប្រាប់ណុងក្រមុំទៅម៉ែនិយាយប្រាប់។

ក៖ អូ៎ចុះអើកាលឆ្នាំប៉ៃត្រជាងហ្នឹងដាច់ប៉ុលពតថ្មីៗមីងមានចាំនៅពេលហ្នឹង?

ខ៖ មានចាំទេអត់ចាំអីផង។

ក៖ យើងអត់ទាន់ចាំទេណេះមីងណេះ?

ខ៖ អត់ទាន់ចាំអីទេ។

ក៖
អូ៎ចុះនៅពេលដែរដល់ឆ្នាំណាដល់ឆ្នាំកៅជាងមីងការម៉ងទាល់តែមីងការម៉ងបានមីងដឹង?

ខ៖
មីងការម៉ែនិយាយប្រាប់ទាំងប្តីមីងអីចឹងទៅនិយាយប្រាប់ចេះមួយចុះមួយទៅបានដឹងពីម៉ែទៅ។

ក៖
អូ៎ចឹងមានន័យថានៅពេលដែរមីងរៀបរាប់ពីការមិញអើឪពុកម្តាយប្រាប់ផងអីផងហាសណេះមីង?

ខ៖ ហ្នឹងហើយ!

ក៖ ដោយសារយើងនៅក្មេងពេកណេះមីង?

ខ៖ នៅក្មេងអត់ដឹង។

ក៖ ចុះរហូតដល់ឆ្នាំកៅជាងកៅជាងមីងដឹងហើយ?

ខ៖
ដឹងហើយដឹងគេនិយាយគ្រប់ៗគ្នាចាស់ៗពីដើមនិយាយប្រាប់ចឹងទៅអូ៎ខ្ញុំអូយជំនាន់ណុងគ្មានដឹងអីទេម៉ាក់យាយអើយ យាយៗគាត់និយាយជំនាន់ពីដើមស្តាប់គាត់និយាយ។

ក៖
បាទមីងចុះគិតថាអើកាលដែរមីងលំបាកហាសកាលនៅក្មេងហាសរហូតទាល់មីងដឹងក្តីហាសមីងមានការលំបាកអីខ្លះទៅពេលណុង?

ខ៖
មើលគោមើលក្របីអីម៉ែអោយមើលគោមើលក្របីឆ្លងផ្លូវអើឆ្លងអាលែងច្បារទឹកហូរអើទឹកឡើងទឹកអីណុងខ្ញុំបីសលួងទឹកលួងអីងាប់ហោសមើលក្របីក្រោយម្ខាងហោសឆ្លងច្បារដល់ពេលយើងទៅពីហ្នឹងទឹកអត់ឡើងដល់មកវិញទឹកឡើង។

ក៖ អើម៉េចចឹងមីង?

ខ៖
ទឹកវាទើបធ្លាក់មកភ្លៀងពីលើដល់ចឹងទៅឡើងគោងកន្ទុយក្របីហ្នឹងទៅអោយក្របីហ្នឹងហែលទឹកបណ្តែតខ្លួនមកចឹងយើងឆ្លងខ្លួនមកផ្ទះមក។

ក៖ អូ៎យើងជិះពីលើក្របីហ្នឹង?

ខ៖
យើងជិះពីលើក្របីវាបណ្តែតនៅធ្វើស្តឹងៗហើយអាមែកឬស្សីវាមកតាមទឹកហូរណុងចេះតែមកទាំងផ្ទាំងៗទៅ។

ក៖ អូ៎!

ខ៖
កំសត់ដែរមីងនៅពីក្មេងដើរមើលគោមើលក្របីម៉ែអោយទៅមើលទៅមើលក្រោយម្ខាងណោះឆ្លងច្បារចឹងទៅ។

ក៖ អូ៎បាទមីង!

ខ៖ កំសត់ដែរណុង។

ក៖
ចុះមីងគិតថារហូតដល់ពេលណាបានយើងចាប់ផ្តើមធូរមីងឆ្នាំពីរពាន់ជាងហើយណោះមីងណោះ?

ខ៖
ហ្នឹងហើយពីរពាន់ជាងណុងមីងតាំងពីបានប្តីមកអត់ដែរនៅជាមួយគាត់ដែរដល់បែកណុង។

ក៖ អូ៎!

ខ៖ អត់ដែរនៅជាមួយម៉ែទេការហើយបានតែតិចធ្វើផ្ទះបែកបណ្តោយ។

ក៖ អូ៎!

ខ៖ អត់មាននៅជាមួយម៉ែឪទេខ្ញុំអត់ចេះនៅរញ៉េរញ៉ៃការហើយបែកទៅ។

ក៖
ប៉ុន្តែទាល់បានកូនធំៗហើយគាត់ចេះទៅធ្វើការធ្វើអីបានយើងចាប់ផ្តើមធូរខ្លាំងហើយណោះមីងណោះ?

ខ៖ ហ្នឹងហើយទាល់កូនទៅរកដែរបានក្លួយអើយបើកូនមិនទៅអត់ហ្នឹងហើយ!

ក៖ អូ!

ខ៖ ទៅណាមកណា។

ក៖ រហូតទាល់តឡូវ?

ខ៖ ហ្អឹងហើយ!

ក៖ តែតឡូវជីវភាពយើងម៉េចទៅមីង?

ខ៖ ជាធម្មតាដូចមិនពិបាកហើយមិននេះដែរដូចថាធម្មតា។

ក៖ តែគ្រាន់ថាកូនចៅគាត់អត់តឡូវគាត់អត់ទាន់ទៅណាទេ?

ខ៖ នៅក្នុងបន្ទុកជាមួយខ្ញុំទាំងពីរ។

ក៖ ប៉ុន្តែយាយទាល់ដល់ខែវស្សាបានយើងធ្វើស្រែវស្សាចឹងទៅ?

ខ៖
ចាំហ្អឹងហៅអាគ្រាក់គេទៅថ្ងៃហ្អឹងមុនទៅភ្ជួរអត់មុតគេឡើងមកវិញមកគេថាភ្ជួរអត់មុតទាល់ភ្ជួរទាល់ទៀងចឹងបានគេថាទាល់តែដីគេភ្ជួរមុនបានគេភ្ជួរអោយ។

ក៖ បាទមីងអូចុះមីងគិតថាចឹងពេលណាយើងចាប់ផ្តើមសប្បាយមីង?

ខ៖ ចាំ!

ក៖ ពេលណាយើងចាប់ផ្តើមសប្បាយក្នុងក្រុមគ្រួសារយើង?

ខ៖ អើខ្ញុំសប្បាយរាល់ថ្ងៃក្មួយបីនាក់ម៉ែកូនគ្មានពិបាកទេ។

ក៖ ចឹងហោសមីងហោស?

ខ៖ ហ្អឹងហើយ!

ក៖ អូ!

ខ៖ បាយទឹកហើយនាំម៉ែកូនដេកប្រាជប្រោចសប្បាយហាស!

ក៖ បីប្អូននាក់ម៉ែកូនយាយចឹងទៅ?

ខ៖ ហ្អឹងហើយយាយចឹងទៅតែប៉ុណ្ណឹងនាក់ហ្អឹង!

ក៖ អូ!

ខ៖ ចាំមីអូនលើកអោយម៉ែម៉ែឯងលើកទឹកក្តៅធ្វើអី។

ក៖
ចុះមីងគិតថាអើចឹងមីងកាលនៅក្មេងមីងធ្លាប់មានគោលបំណងថាធំឡើងមីងចង់ធ្វើអីមួយ ដូចធ្វើប៉ូលីស ធ្វើពេទ្យធ្វើអីមួយមីងធ្លាប់គិតអត់?

ខ៖
គិតអីបើអក្សររៀនមិនចេះផងលោកគ្រូយើងទៅរៀនអីដឹងក្តីមកម៉ែអោយការមកមិនដែរដើរទៅរកអី។

ក៖ អូបាទមីង!

ខ៖
មានដែរដើររកអីទេខ្ញុំមកនៅជាមួយម៉ែការហើយដឹងតែធ្វើស្រែធ្វើចំការដល់បែកពីម៉ែមកពី

រនាក់ប្តីប្រពន្ធក៏នៅតែធ្វើស្រែ
ប៉ុនពីដើមមកមីងអត់ទាន់មានដីស្រែទេក្មួយអើយមីងដើរជួលដីស្រែគេធ្វើ។

ក៖ ចឹងហោសមីង!

ខ៖
ហ្នឹងហើយហើយម៉ែឳចែកទ្រព្យរបស់ដូចថាដូចជាគោអីចឹងយើងជំនាន់ណុងយើងភ្ជួររទេះយើងភ្ជួរគោហាស!

ក៖ បាទមីង!

ខ៖ ពីនាក់ប្តីប្រពន្ធជួលស្រែគេធ្វើទៅ។

ក៖ ចឹងមានន័យថាយើងមានគោយើងអាចទៅភ្ជួរស្រែគេ..?

ខ៖ ភ្ជួរស្រែគេធ្វើ។

ក៖ ដល់ពេលចឹងយើងចែកអោយគេម៉េចមីង?

ខ៖
គេចែកដូចថាក្នុងមួយហត្ថប៉ុន្មានពីរហត្ថប៉ុន្មានប៉ោតមួយឆ្នាំហ្នឹងជូនកាលគេយកសាមសិបប៉ោតចឹងទៅ ហើយក្របីគេយកហាសិបប៉ោតចឹងទៅ។

ក៖ អូ៎!

ខ៖ ម្ខាងហាស!

ក៖ បាទសល់ប៉ុន្មានយើងទាំងអស់?

ខ៖ សល់ប៉ុន្មានយើងទាំងអស់ទៅ។

ក៖ រួចជាទូទៅមួយឆ្នាំយើងបានប៉ុន្មានប៉ោតទៅមីង?

ខ៖ មួយឆ្នាំពីររយហាសិបប៉ោតអីចឹងទៅ។

ក៖ គេយកហាសិបប៉ោតអីយើងសល់ពីររយចឹងទៅ?

ខ៖
យើងផាត់ហ្នឹងហើយយើងផាត់ថ្លៃគោថ្លៃក្របីថាអស់មួយរយចឹងទៅហើយដីអស់មួយរយប៉ោតចឹងទៅនៅមួយរយហាអីដែរ។

ក៖ អូ៎អាហ្នឹងយើងខំប្រឹងភ្ជួរ?

ខ៖
ហ្នឹងហើយដល់ឳក្មេកខ្ញុំថាកូនអើយឳចាប់ដីព្រៃបានហើយកូនឯងទៅរុកទៅរានធ្វើទៅឳក្មេកខ្ញុំណុង។

ក៖ បាទមីង!

ខ៖
ហើយក្មួយអើយទៅរុកទៅរានកំសត់មហាសែនកំសត់នេះនិយាយពីលិចដំរីស្មៅហាសទៅរុកទៅរានដីរាល់ថ្ងៃហ្នឹងហាស!

ក៖ បាទមីង!

ខ៖ មីងទៅរុកទៅរៀនពីរនាក់ប្តីប្រពន្ធប្តីហ្នឹងនេះមីងហ្នឹងក្រោយ
ក្រោយស្មៅហ្នឹងប្តីហ្នឹងអ្នកទៅរាស់រនាស់ រាស់រនាស់ទៅ។

ក៖ បាទមីង!

ខ៖ រុករានដីហ្នឹងបានបានមីងធ្វើរាល់ថ្ងៃហ្នឹង!

ក៖ អូ៎!

ខ៖
អាឡូមានធ្វើអីអង្គុយប្រាជលេងជាមួយលោកគ្រូបានហើយចឹងខ្ញុំរវល់បន្តិចដល់ពេលរុករានណុងបានហើយអីហើយចឹងស្រលះកើតដូចថាស្រលះចឹងទៅខ្មោចឪក្មេកខ្ញុំថាកូនចៅអើយទៅធ្វើផ្ទះអីធ្វើរោងអីធ្វើស្រែនៅណុងម៉ងទៅកូនអើយលើកភ្លឺលើកអីណុងម៉ងទៅរុករានដីណុងទៅទៅធ្វើស្រែធ្វើអីណុងបានរស់ហ្នឹងបានទាល់សព្វថ្ងៃដីខ្លួនឯងអីខ្លួនឯងរុករានខ្លួនឯង!

ក៖ ចឹងមានន័យថាយើងមែនទិញគេណាហី?

ខ៖
អត់ទិញទេឪក្មេកដូចថាដើរចាប់ដីចោលៗចឹងឪក្មេកចេះតែដើរចាប់ទៅហើយកូនចៅចែកម្នាក់មួយប្លង់ៗអោយដើររុករានទៅក្បាលម្នាក់មួយរយម៉ែត្រវីមួយក៍ពីររយម៉ែត្រចឹងទៅ។

ក៖ បាទមីង!

ខ៖ ហើយអោយរុករានធ្វើខ្លួនឯងយកទៅចឹង។

ក៖ ចុះដីរាល់ថ្ងៃហ្នឹងប៉ុន្មានម៉ែត្រទៅមីង?

ខ៖ ដីរាល់ថ្ងៃដីមីងទាំងអស់ចូលប្រាំហត្ថ។

ក៖ ប្រាំហត្ថហោស?

ខ៖ ហ្នឹងហើយ!

ក៖ អូ៎ច្រើនដែរចឹង?

ខ៖ ច្រើនរុករានហ្នឹងដល់ខ្ញុំលែងគ្នាទៅខ្ញុំចែកពុះចែកគ្នាពាក់កណ្តាលម្នាក់ចឹង។

ក៖ យើងបានម្នាក់ពីរហត្ថកន្លះទៅ?

ខ៖ ហ្នឹងហើយពុះពាក់កណ្តាលប៉ុន្តែដីខ្ញុំអត់ទាន់រានអស់ហើយព្រៃក៍អត់ទាន់រានអស់ដែរ។

ក៖ បាទមីងចុះមួយឆ្នាំយើងធ្វើបានប៉ុន្មានទៅមីង?

ខ៖
ក៍កើតបានមួយរយហាក៍មិនកើតចឹងទៅបានមួយរយសាមមួយរយម្ភៃមួយរយដប់បើមិនកើតសោះបានចិតប៉ែត្រចឹងទៅក្អួយវាមិនទៀងហាស!

ក៖ បាទមីងបាទអូ៎ប៉ុន្តែចេះតែបានហើយមីងណេះ?

ខ៖ បានតិចច្រើនមិនបានថាអត់សោះអត់ទេ។

ក៖ អូ៎ចឹងសព្វថ្ងៃយើងពឹងផ្អែកទៅលើស្រែហ្នឹងទៅ?

ខ៖ ពឹងផ្អែកលើស្រែចឹងទៅក្អួយអើយមិនដឹងរកអី។

ក៖ កូនចៅគាត់នៅផ្ទះចឹងទៅ?

ខ៖ ហ្នឹងហើយ!

ក៖ អូ៎ពិបាកដែរចឹង?

ខ៖ ពិបាក។

កៈ ចុះ..?

ខៈ ពេលចាំ!

កៈ មីងម៉េចមីង?

ខៈ
ពេលកូនចៅដើរទៅស៊ីឈ្នួលគេចឹងទៅបានមកទៅវាអផយម៉ែទៅព្រោះអត់គេធ្វើការដែរចឹង
នៅជុំម៉ែកូនចឹងទៅ។

កៈ ដាទូទៅគាត់ទៅធ្វើស្អីគេទៅមីងនៅភ្នំពេញនៅ..?

ខៈ នៅភ្នំពេញកូនខ្ញុំធ្វើកន្លែងហាងប្រហិតគេហី!

កៈ អូ៎គាត់មែនទៅធ្វើការនៅរោងចក្រណាហី?

ខៈ អត់ទេធ្វលើរោងចក្រអត់កើតមីអូនវាចេះតែថប់ៗដូចតែខ្ញុំដែរហ្នឹងមីងបងហាស!

កៈ បាទបងស្រីមិញ?

ខៈ ហ្នឹងហើយមីបងមិញហ្នឹងចេះតែអោយតែធ្វើការហាលក្តៅតិចថប់ហើយ!

កៈ អូ៎!

ខៈ ដល់ចឹងខ្ញុំអត់ហ៊ានអោយទៅរោងចក្រព្រោះអីវាខ្សោយ។

កៈ បាទមីង!

ខៈ ចង់អោយធ្វើខែទៅនៅភ្នំពេញហ្នឹងធ្វើប្រហិតចឹងជួនកាលបួនដប់ថ្ងៃគេធ្វើម្តង
ចឹងទៅមួយខែបានមួយរយហា។

កៈ អូ៎ប៉ុន្តែគាត់អត់ទាន់មានគ្រួសារណាហីមីងណេះ?

ខៈ អត់មានគេថាគេអត់យកគេចាំយកកូនមីអូនបួនណុងថា។

កៈ អើ..!

ខៈ គេសួរដែរតែគេមិនយកដឹងទៅធ្វើម៉េចក្លួយអើយ!

កៈ ទីពីរហ្នឹងក៏អត់យកដែរ?

ខៈ មីទីពីរវាថាគេសួរអោយយកមីទីពីរវាអត់យកទេវានៅចិញ្ចឹមម៉ែ។

កៈ អត់ទាំងពីរនាក់?

ខៈ គេថាមីទីពីរគេដេញអោយមីទីពីរយកទៅគេមីបងគេថានៅចិញ្ចឹមម៉ែ។

កៈ បាទ!

ខៈ គេអត់យកទេ។

កៈ ប៉ុន្តែទីពីរក៏ថាអត់យកដែរ?

ខៈ
ទីពីរគេយកបើសិនជាមានគេសួរគេយកហើយប៉ុន្តែគេសួរដែរប៉ុនគេថាមនុស្សវាមិនកើតយើ
ងអោយធ្វើម៉េចក្លួយអើយ!

កៈ អូ៎!

ខៈ
ខ្លាចយកកូនយើងទៅធ្វើបាបគេសួរដែរយើងមើលមនុស្សដូចថាវាយើងមើលសួរសាវតាបានតាមប្រវត្តិដែរយើងមិនចេះតែអោយៗទេ។

កៈ បាទីងត្រូវខ្លាចគេធ្វើបាបកូនយើងអីទណេះមីង?

ខៈ ខ្លាចគេធ្វើបាបកូនយើងដូចអាកូនខ្ញុំអោយរាល់ថ្ងៃនេះមិនបានសួរប្រវត្តិហ្នឹងហាស!

កៈ អូ៎!

ខៈ
ដល់មិត្តភក្តិខ្ញុំគេដើរហុចជៀបទៅថាអោយនរណាអោយកូនគាហេងយើងវាស្តាយក្រោយដែរតែវាហួសពេលហាស!

កៈ បាទមីង!

ខៈ
ប៉ុនខ្ញុំគ្រាន់តែហាមមុខនៅងន្លងខ្ញុំថ្ងៃមុននេះខ្ញុំនិយាយថាបើសិនតែត្រូវកូនខ្ញុំមួយរំពាត់ជួយអត់បានទេកូនខ្ញុំមានតែបីគ្រាប់ដូចគ្រាប់កណ្តឹងចឹងអត់ដែរគោះទេ
ហើយក៏មិនដែរវៃកូនខ្ញុំដែរតែឥឡូវវាខូចវានិយាយអត់ដឹងអីទេប្តីវាណុងដូចថាវានៅក្មេងក្មេងប្អូនកូនខ្ញុំមួយឆ្នាំប្តីវាហ្នឹង!

កៈ ប្តីកូនមីងសព្វថ្ងៃហ្នឹង?

ខៈ ហ្នឹងហើយមីមួយដែរការហើយហ្នឹង!

កៈ អូ៎!

ខៈ មីប្អូន។

កៈ ដែរបានកូនមួយមកហ្នឹងហោស?

ខៈ ហ្នឹងហើយវានិយាយអត់ដឹងអីទេអាណុងមនុស្សអត់ដែរចូលសាលាហាស!

កៈ បាទមីង!

ខៈ
មនុស្សអត់ដែរចូលសាលាវាដូចថាអន្តោប្រវេសប៉ុន្តែកូនខ្ញុំវាចាស់ចិត្តចាស់គំនិតវានិយាយដឹងខុសដឹងត្រូវ។

កៈ បាទមីង!

ខៈ
តែអានោះវាអត់ប្រាប់ខ្ញុំថាបើទ្រាំអត់បានខ្ញុំអត់បំបែកបំបាក់កូនទេគ្រាន់ខ្ញុំប្រាប់ថាបើកូនទ្រាំបានទ្រាំ បើកូនទ្រាំមិនបានម៉ែអត់បំបែកបំពាក់កូនទេលើស៊ីសងលើកូន។

កៈ ត្រូវមីង!

ខៈ
ហើយកូនហ្នឹងគេថាបើខ្ញុំទ្រាំលែងបានក៏ខ្ញុំប្រាប់ម៉ាក់ឯងដែរខ្ញុំចុះគ្មានយកអីទេគេនិយាយចឹង។

កៈ ប៉ុន្តែកូនរបស់មីងក្មេងដែរតើណេះមីងណេះ?

ខៈ ក្មេងមីទៅអូសអេកូថ្ងៃមុនគេហៅថាកូនបីខុសគេតែមីហ្នឹងមួយគេថាហាស!

កៈ អូ៎!

ខៈ កូនមីងឯងមីហ្នឹងមួយដូចបារាំងចឹងកាត់ទៅណាហើយចុះដឹងម៉េច។

កៈ អូ៎បាទមីងប៉ុន្តែមីងមានចៅប៉ុន្មានចៅទើបម្នាក់តើហី?

ខៈ ចៅទើបបានចៅមួយណុង។

កៈ អូ៎!

ខៈ ចៅបង្កើតណុងបានតែមួយណុង។

កៈ
បាទមីងចុះបើសិនជាចង់អោយមីងសំនួរចុងក្រោយមីងបើសិនជាចង់អោយមីងផ្ដែផ្ដាំទៅកូនចៅជំនាន់ក្រោយអីចឹងហាសណាស់?

ខៈ ហ្នឹងហើយ!

កៈ មីងមានពាក្យពេចន៍អីដែរចង់ផ្ដាំផ្ញើរទៅកូនចៅជំនាន់ក្រោយៗរបស់មីងអត់មីង?

ខៈ
មានតែផ្ដាំផ្ញើរដូចនិយាយជាមួយលោកគ្រូឯងណុងហើយម៉ែថ្លាប់ឆ្លងកាត់ពិបាកស្រណុកម៉េចនិយាយហ្នឹងប្រាប់វាដែរតើប្រាប់តាំងពីនៅក្រមុំហាសម៉ែឪខ្ញុំប្រាប់ថាម៉ែហត់ម៉េចអីម៉េចចឹងហាស!

កៈ បាទមីង!

ខៈ ប្រាប់កូនអស់ហើយកូនឯងប៉ុណ្ណឹងៗហត់អីសម័យម៉ែជាន់អង្ករបុកអង្ករស៊ីម៉ែមិនថាហត់រែកទឹកម៉ែមិនថាហត់ឥឡូវទឹកដល់ផ្ទះអង្ករដល់ផ្ទះកុំថាហត់អីប៉ុណ្ណឹង!

កៈ អូ៎បាទមីង!

ខៈ ឧស្សាហ៍ប្រាបកូនដែរហ្នឹង!

កៈ ប៉ុន្តែមីងមានធ្លាប់ប្រាប់គាត់អោយខំប្រឹងរៀនអោយកូនចៅអីចឹងហាសណាស់?

ខៈ
ហ្នឹងខ្ញុំចាប់ផ្ដើមលែងជាមួយឪវាខ្ញុំថាកូនរៀនទៅម៉ែធ្វើតែម្នាក់ឯងក៏បានដែរវាថាម៉ែហត់ចឹងវាឈប់រៀនមីកណ្ដាលថ្នាក់ទីប្រាំបីមីបងថ្នាក់ទីប្រាំពីរ។

កៈ ពួកគាត់ទើបឈប់ដែរណេះមីងនេះ?

ខៈ ហ្នឹងហើយ!

កៈ អូ៎!

ខៈ
ខ្ញុំអោយវារៀនតើមីកណ្ដាលហ្នឹងជាប់អាហារូបករណ៍ហោសវាមិនទៅឈប់រៀនទៅលែងបានអីទៅ។

កៈ ចឹងហោសមីង?

ខៈ ទើបបើកបានពីរដងណុង។

កៈ អូ៎កាលគាត់រៀននៅថ្នាក់ទីប្រាំពីរទីប្រាំបីហ្នឹង?

ខៈ ហ្នឹងហើយរៀនសាលាទីប្រាំបួនណុង។

កៈ អូ!

ខ៖ កណ្ដាល។

ក៖ ខាងសាលាគេអោយជាប់ហោស?

ខ៖ សាលាគេអោយជាប់គ្រូគេសួរសំនួរអោយយើងឆ្លើយនោះហើយ...!

ក៖ ចឹងមានន័យថាគាត់រៀនពូកែហាសណោះមីងណោះ?

ខ៖ រៀនឆ្លាតតើមីកណ្ដាលណុងរៀនថ្នាក់ទីប្រាំបីលើមីបង។

ក៖ ម្នាក់ស្រីមិញហ្នឹងហោសមីង?

ខ៖ ហ្នឹងហើយពាក់ខោអាវព័ណត្រួយចេកមិញណុង។

ក៖ ជិះម៉ូតូឌុបក្មួយទៅហ្នឹងហោស?

ខ៖ ដែរយកព្រីងទៅអោយអាអូនណុង។

ក៖ ខ្ញុំមកអត់ទាន់ផង។

ខ៖ អើ!

ក៖ អត់ជួបផង!

ខ៖ អង្គុយបត់ខោអាវនៅទីនេះមិញ។

ក៖ អូ៎ហ្នឹងកណ្ដាល?

ខ៖ ហ្នឹងហើយកណ្ដាលរៀនថ្នាក់ទី..។

ក៖ ចុះបងគេ?

ខ៖ បងគេ។

ក៖ ឌុបក្មេង?

ខ៖ ហ្នឹងហើយពាក់អាវការ៉ូបត់ទៅមិញឌុបអាអូនទៅមិញហោស!

ក៖ អូ៎!

ខ៖ ណុងបងហើយណុងហោសបងតូច។

ក៖ ចឹងខាងណោះកណ្ដាលវិញ?

ខ៖ ហ្នឹងហើយអង្គុយមិញហ្នឹងកណ្ដាលទេ។

ក៖ កណ្ដាលមាឌធំជាងបង?

ខ៖ កណ្ដាលមាឌធំជាងបង។

ក៖ អូ៎ខ្ញុំស្មានតែនេះកណ្ដាលអើបងគេតើមិញ?

ខ៖ ទេគេថាអាកណ្ដាលហ្នឹងបងគេណុង។

ក៖ បាទគាត់មាឌធំ?

ខ៖ ធំតែគ្នាមិនសូវចេះមាត់ទេអូ៎អើយមីកណ្ដាលមិនសូវទេ។

ក៖ បាទ!

ខ៖ ចឹងបានមិនហ៊ានដើររកស៊ីឆ្ងាយទេគ្នាអត់សូវចេះមាត់។

កៈ បាទមីង!

ខៈ បើមីបងអត់ខ្លាចគេទេទៅភ្នំពេញតាំងពីកំពស់នេះអត់សូវចេះមាត់ទេខ្លាចពីណាទេ។

កៈ បាទ!

ខៈ អាណុងហោសមីបងហោស!

កៈ
ចុះមីងមានធ្លាប់ទូន្មានព្រានប្រដៅកូនកូនចៅកុំអោយពួកគាត់ភ្លើតភ្លើនដើរផ្លូវខុសដូចលក្ខណៈជក់គ្រឿងញៀនមីងមានធ្លាប់ព្រានប្រដៅពួកគាត់ទេមីង?

ខៈ
អូ៎កូនចៅខ្ញុំតាំងពីបែកឪវាមកខ្ញុំមិនដែរពិបាកនិយាយទេអត់ដែរចុះម៉ែគាត់ទៅណាទៅឆក់ដែកចៅទុកអោយគាត់ផង
អើបើនិយាយទៅតាំងពីបែកពីឪវាមកកូនខ្ញុំសូម្បីតែនៅជាមួយឪវាក៏ដោយមិនដែរពិបាកនិយាយពីរឿងការដើរហើរ ទូរស័ព្ទប្រុសឈ្លោលអីមិនដែរពិបាកនិយាយទេ។

កៈ អូ៎!

ខៈ គឺដឹងគិតខ្លួនវាទៅរកស៊ីខេត្តមួយទៅខេត្តមួយទៅរតនៈគិរីទៅក្រុមហ៊ុនយកនិគ្រីន
ទៅពូជ្រៃទៅណាក៏ទៅដែរកូនខ្ញុំ។

កៈ អោយតែរកលុយបាន?

ខៈ
អោយតែរកលុយបានតែមិនដែរភ្លើតភ្លើនចឹងអត់មានសោះសួរញ្ញាតិជិតខាងទៅមិនដែរមានទេអត់សោះ។

កៈ យើងប្រាប់តែរហូតណេះមីង?

ខៈ
មិនងាយទេគ្រាន់តែចេញទៅគ្រាន់តែផ្តាំតែប៉ុននេះថាកូនដឹងអ្វីមួយល្អអ្វីមួយអាក្រក់កូនត្រូវចេះគិតស្រឡាញ់ខ្លួនកូន។

កៈ បាទមីង!

ខៈ អនាគត់កូននិយាយតែប៉ុណ្ណឹងទេ។

កៈ អូ៎!

ខៈ
ហើយគេឆ្លើយមកគេថាម៉ែប៉ុនៗណេះហើយខ្ញុំចេះដឹងល្អដឹងអាក្រក់ហើយហើយមែនមិនដែរពិបាកនិយាយទេ
មិនដែរពិបាកនិយាយចង់គេដាក់ធុងបាសអង្គើដីណុងដេកលើផ្ទះចឹងនរណារាំអីរាំទៅអត់ខ្វល់នៅតែមើលទូរសទស្សន៍វីឌីអូហ្នឹងទៅ។

កៈ អូ៎!

ខៈ
មិនដែរពិបាកនិយាយរឿងប្រុសឈ្មោលអត់ទូរស័ព្ទមាននៅដៃចាក់ទុកក្នុងហិបអត់ចេះនិយាយដូចគេអូនបងណាណីអត់ទេ
គ្មានពិបាកនិយាយពីរឿងចឹងៗសូម្បីពូសៅនៅទីបួនក៏គាត់លួចសរសើរដែរថាកូនមីងវន្តតាំងពីឃើញដឹងក្តីមកមិនដែរពិបាកនិយាយពីរឿងប្រុសឈ្មោលអីអត់ទេ
ខ្លះអត់ពីឪចេះឡើងចៅហើយចង់ធ្វើអំពើពាលខ្លួនឯង!

កៈ បាទមីង!

ខៈ
តែកូនខ្ញុំអត់ទេអត់ធ្វើចឹងទេឃើញគេធ្វើហ្នឹងវាថាអត់ចេះស្រឡាញ់ខ្លួនអត់ចេះខ្មាស់គេចឹង
ហាស!

កៈ បាទមីងបាទ!

ខៈ ឃើញដូចថាមិត្តភក្តិអីធ្លាប់ស្គាល់គ្នាគេធ្វើចឹងអីចឹងវាមកនិយាយប្រាប់យើងចឹងទៅ។

កៈ អូ៎!

ខៈ
ខ្ញុំមិនទៅធ្វើអាចរឹតថោកទាបគ្មានស្អីដណ្តឹងមកដល់ម៉ែឪមិនទៅរត់តាមនរណាទេវានិយាយ
ចឹងវានិយាយខ្លួនវាចឹងទៅ។

កៈ បាទមីង!

ខៈ មានទៅពិបាកណែនាំទេកូនបីហើយមិនពិបាកណែនាំទេទាំងអស់។

កៈ ប៉ុន្តែកូនមីងស្រួលៗទេណេះមីង?

ខៈ ស្រួលចិញ្ចឹមចឹងបានខ្ញុំថាខ្ញុំធ្វើបុណ្យជាតិហ្នឹងវាមិនចំអាកូនដើរលក់មុខយើងហាស!

កៈ បាទមីង!

ខៈ វាអត់ចំអាកូនចឹងអូ៎បើកូនចឹងទៀតខ្ញុំងាប់ហើយងាច់ខ្យល់ងាប់ម៉ង។

កៈ អត់ពីប្តីហើយ!

ខៈ ហ្នឹងហើយកូនធ្វើចឹងទៀតតែកូនដោយកន្លងផមដែរ។

កៈ បាទមីង!

ខៈ ចេះដឹងល្អអាក្រក់ខ្លួនវាដែរ។

កៈ បាទមីង!

ខៈ
ចឹងបានខ្ញុំថាខ្ញុំសុំសរសើរកូនដែរនេះមែននិយាយលើកជើងកូនខ្លួនឯងទេតែយើងអាណា
ព្យាបាលយើងដឹង។

កៈ បាទមីងបាទត្រូវ!

ខៈ យើងមើលថៃកូនយើងដឹងអ្វីមួយល្អអ្វីមួយអាក្រក់
ក្មេងណាដែរវាភ្លើតភ្លើនវាទៅប្លែកទៅ។

កៈ បាទមីង!

ខៈ
យើងមើលដឹងតែព្រលប់ឡើងចូលផ្ទះដេកហើយតែម៉ោងប្រាំមួយម៉ែកូនចាក់សោរដេកហើយ
នៅទីហ្នឹងដាក់កន្លឹះដេកហើយចង់គេរាំក៏ដោយម៉េចក៏ដោយអោយវាទៅជាមួយម៉ែវាមិនឌុប
ទៅផងវាសុខចិត្តនាំគ្នាដេកតែជាមួយម៉ែកូនហ្នឹងទៅមិនទៅណាទេ។

កៈ អូ៎!

ខៈ ត្រូវគេទៅទៅគេចង់ទៅថាតោះម៉ែទៅមើលគេមួយភ្លេតចឹងទៅឌុបទៅ។

កៈ អ្ហ៎!

ខៈ
ស្រួលទាំងអស់ចឹងបានមីងថាអត់ពីប្តីហើយកូនពិបាកនិយាយទៀតប្រះទ្រូងដាប់ម៉ងសូម្បីតែស្លៀកខ្លីហ្នឹងតាំងពីរស់នៅហ្នឹងទីបួនហ្នឹងកូនខ្ញុំមិនដែរស្លៀកស្លីអោយគេឃើញក៏មិនដែលដែរ គេសរសើរគ្រប់តែគ្នាតើ!

កៈ បាទមីង!

ខៈ អត់ពីឪគេដូចថាវាមិនធ្វើពាលខ្លួនឯងដើរហើរសើរីអីមិនដែរពិបាកនិយាយទេ។

កៈ បាទ!

ខៈ ចឹងបានខ្ញុំថាធ្វើជាតិមុនវាល្អហើយយ៉ាងបានជួបកូនវាមិនធ្វើចរឹតចឹងហោស!

កៈ បាទមីង!

ខៈ
បើឃើញគេធ្វើចឹងវាថាតើវាថាអត់ចេះអាណិតម៉ែឪទេម៉ែឪទូលស្បែកឆ្អែណាណីវាចេះនិយាយទៅ។

កៈ អ្ហ៎!

ខៈ បើចឹងវាចេះថែរក្សាខ្លួនគេគ្មាននៅដល់ប៉ុនណេះទេបើអ្នកខ្លះហ្នឹងវាទៅបាត់ទៅហើយ!

កៈ ត្រូវមីងត្រូវ!

ខៈ មីមួយដែរការហ្នឹងទូរស័ព្ទទិញមកអាល្អតំលៃបីរយហ្នឹងទុកតែក្នុងហិបមិនដែរនិយាយទេត្រូវការទៅរកស៊ីណាចឹងទៅកាន់ទៅស្រណុកម៉ែតេទៅហើយបើមិនទៅតេហ្នឹងនៅតែក្នុងហិបម៉ង
ខ្ញុំថាអើទូរស័ព្ទដាក់ចោលក្នុងហិបអាណាតេមកក៏មិនដឹងដែរកូនឯងទិញមកធ្វើអីចឹងមិនដឹងយកមកប្រើចេះនិយាយថាម៉េចទេម៉ែនិយាយចឹងទៅ។

កៈ អ្ហ៎!

ខៈ
វាស្រួលទាល់មានប្តីហ្នឹងក៏ដោយទូរស័ព្ទក៏មិនរវីរវល់និយាយអីដែរច្រើនដែរនិយាយតែពីរឿងលក់ដូរណុងគេហៅតវ៉េតវ៉ាន់តែប៉ុណ្ណឹងហើយហើយ!

កៈ បាទមីង!

ខៈ
ចឹងបានថាកូនបីហ្នឹងវាស្រួលនិយាយដែរចង់បានញ៉ូរកន្ទុយជាងមីបងៗទាំងអស់ណុងទៀតណុងដឹងតែពីចង់បានតែម៉ង។

កៈ កូនទីបីហ្នឹងហោស?

ខៈ មីកូនទីមីពៅគេណុង។

កៈ អ្ហ៎!

ខៈ
ចង់បានញ៉ូរជាងគេម៉ងនឹកឃើញសំឡត់ប្តីបង្គោលរបងប៉ុនៗហ្នឹងវាអោយលីមួយថ្ងៃសាមសិបបង្គោលអាណាធ្វើតាមវាកើតចង់បានញ៉ូរអស់ហើយអាប្តីហ្នឹងអត់ចង់បានទេទំនុកបំរុងអីលើកូនយើងទាំងអស់វាថាពីក្មេងវាអត់យល់សាច់ការណ៍អីសោះ។

កៈ បាទមីង!

ខៈ
ទៅអាកូនយើងចង្អុលបត់បញ្ហាធ្វើចេះៗចឹងទៅវាដូចអត់សូវយល់សាច់ការណ៍ចឹងហាសណាស់
។

កៈ បាទមីងបាទ!

ខៈ
បើខាងដើរព្រៃដើរអីអាហ្នឹងបាញ់សត្វបណ្ដើរឆ្កែអាហ្នឹងជានាហើយបើរឿងថាធ្វើការងារក្នុង
ផ្ទះអាហ្នឹងមិនសូវទេវាហ្នឹងមិនសូវច្បាស់លាស់ទេលក់ដូររាល់ថ្ងៃហ្នឹងសួរប្រពន្ធមិនដឹងថាលក់អី
ប៉ុន្មានៗអត់ដឹងទេ។

កៈ ចឹងហោសមីង?

ខៈ
អត់ជួយមើលជួយអីវាម៉េចដឹងវាដូចថាប្រពន្ធលក់ដាច់ខ្លាំងចឹងមែនប្ដីខ្លះគេជួយមើលជួយ
លក់វាដេកមើលទូរស័ព្ទធ្វើមិនដឹងចឹងទៅ
ដល់ពេលដល់ប្រពន្ធទៅណាវាសួរថាអានេះមួយដប់ប៉ុន្មានគេសួរប្រពន្ធទៅណុងអត់យល់ទេចឹ
ងបានថាកូនខ្ញុំដឹកមុខណុងបើនិយាយប្រៀបអាជន្លះទៅអាឆ្អៀបានឆាបទៅបើមិនឆ្អៀមិន
ឆាបទេ
ណុងចឹងបានខ្ញុំថាអោយកូនខុសហើយកូនល្អអោយខុសហើយខ្ញុំរាល់ថ្ងៃស្ដាយកូនដែរតើ!

កៈ អូ៎!

ខៈ
ប៉ុន្តែខ្ញុំថាតែមួយម៉ាត់កុំរវីតែរវីរឿងហើយខ្ញុំលូកដៃបើអត់ត្រឹមម៉ាឈ្លោះៗចុះរឿងរបស់អ្នកឯ
ងតែរវីកូនខ្ញុំលូកដៃហើយខ្ញុំចូលលូកដៃហើយ!

កៈ បាទមីង!

ខៈ
តែគេបានតែគំរាមទេវាមិនដែររវីទេដល់ថ្នាក់កូនខ្ញុំថាឥឡូវអញ់ទ្រាំលេងបានហើយនេះអញ់
ហៅទៅផ្ទះប្រធានភូមិ
វាថាទៅផ្ទះប្រធានភូមិធ្វើអីមែនប្រធានភូមិការអោយវាណាម៉ាក់ប៉ាតើការអោយវាចប់ត្រឹមវា
និយាយចឹង មិនដឹងនិយាយថាម៉េច។

កៈ បាទមីងបាទ!

ខៈ
ហើយដល់ហើយបានខ្ញុំថាប្រធានភូមិហ្នឹងគេអ្នកច្បាប់ទំលាប់មុនហ្នឹងការអញ់មានច្បាប់មា
នទំលាប់ទៅឡើងច្បាប់ហែងនិយាយអោយល្អល្អចជាមួយអញ់ផងចឹងចឹងគេមកមិញហ្នឹងខឹ
ងប្ដីប្រពន្ធវាតែខឹងមិនបានយូរទេអូនអើយ
ញ្ញេសបានតែដូចថាមួយម៉ោងអីហ្នឹងត្រូវគ្នាទៅស្ដីប្រពន្ធហ្នឹងទៅតាមមីណុងអត់ស្ដីតែវាហ្នឹង
ញ្ញេសញ្ញេសៗចឹងទៅដូចថាមនុស្សគ្នាកាលគេកំលោះគេរវី
ដូចថាវាសរសៃប្រាសាទមិនដឹងទេគេរវីបែកម៉ាត្រឹមហ្នឹងមកនេះ។

កៈ បាទមីង!

ខៈ
បែកឡើងសម្លាកម៉ាប៉ុណ្ណឹងមិនជិតអីណារយៃសថាងាប់ហើយតើគេបង់អោយប្រាំមួយពាន់
គេថាងាប់ហើយតើ!

កៈ ប្រុសហោស?

ខៈ ណុងហើយអាកូនប្រសាររាល់ថ្ងៃហ្នឹង!

កៈ
អ៊ូចឹងមានន័យថានៅពេលដែរយើងយកយើងខាងកូនប្រសារមកហ្នឹងយើងអត់ដឹងហាណេះមីងណេះ?

ខៈ អត់ដឹងមីងអត់បានដឹងផង។

កៈ អត់ដឹងប្រវត្តិទេ?

ខៈ អត់បានសួរប្រវត្តិសាវតាហ្នឹងអីគេបើដឹងមីងសួរហើយ!

កៈ
បាទមីងចឹងចុងក្រោយខ្ញុំអរគុណច្រើនមីងដែរបានអោយខ្ញុំពិភាក្សាជាមួយមីងទាក់ទងពីប្រវត្តិរបស់មីង?

ខៈ ឡូ។

កៈ បាទ!

ខៈ អាឡូលីទេពៅ។